

# ស្ថានភាពមិនទៀងទាត់នៃពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃ:

## ការឆ្លុះបញ្ចាំងពីលំហូរចេញនៃពលករទេសន្តរប្រវេសន៍កម្ពុជានិងមេរៀនបទពិសោធន៍


**ដោយបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ (MMN)**

Mekong Migration Network (MMN)



**ឧបត្ថម្ភដោយ: OPEN SOCIETY FOUNDATION**

*(បកប្រែក្រៅផ្លូវការដោយលោក**សួង សុភាព** ប្រធានគ្រប់គ្រងតំបន់បន្ទាយមានជ័យ*

*នៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ-CWCC)*

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ចំពោះអ្នកដែលបានយកពេលដ៏មានតម្លៃនិងជំនាញរបស់ខ្លួនក្នុងការចូលរួមចំណែកដល់ការស្រាវជ្រាវនេះ រួមទាំងការសរសេរនិងផលិត របាយការណ៍នេះឡើង។ ការបោះពុម្ពផ្សាយនេះ ក៏មិនអាចធ្វើទៅបានដែរ បើមិនមានការចូលរួមពីបណ្តាអ្នកទាំងឡាយនិងអង្គការដូចតទៅ:

* ពលករទេសន្តរប្រវេសន៍និងគ្រួសាររបស់ពួកគេ នៅក្នុងប្រទេសថៃនិងប្រទេសកម្ពុជា ដែលបានផ្តល់នូវពេលវេលានិងការយល់ឃើញក្នុងពេលផ្តល់ការសម្ភាសន៍
* មន្ត្រីរដ្ឋាភិបាលកម្ពុជានិងថៃ ដែលបានផ្តល់ជូននូវចក្ខុវិស័យ និងជំនាញក្នុងពេលផ្តល់ការសម្ភាសន៍
* លោកសួង សុភាព និងក្រុមការងារនៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ដែលបានធ្វើការសម្ភាសន៍ពលករ ថតរូបភាពនៅតំបន់ព្រំដែន និងបកប្រែឯកសារសម្ភាសន៍និងរបាយការណ៍
* លោកមុំ សុខចារ និងក្រុមការងារនៅអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី ដែលបានធ្វើការសម្ភាសន៍ពលករនិងបកប្រែឯកសារសម្ភាសន៍
* លោកឆន ឆៃយុទ្ធ និងក្រុមការងារនៅសមាគមន៍នារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងអ្នកស្រីចាន់ សុគន្ធា និងក្រុមការងារនៅសមាគមន៍អាដហុក ដែលបានធ្វើការសម្ភាសន៍ពលករ
* លោកសុធិឆ័យ វើក់យាំឌី និងក្រុមការងារនៅមូលនិធិហ្សារ និងបុគ្គលិកនៅមូលនិធិម៉ាប និងបុគ្គលិកមូលនិធិរ៉ាក់ថៃ ប្រចាំការិយាល័យខេត្តត្រាត សម្រាប់ការសម្របសម្រួល និងបកប្រែឯកសារសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាននិងពលករ
* កញ្ញាអុមស៊ិន ប៊ូនលើត ដែលជាមន្ត្រីស្រាវជ្រាវនិងតស៊ូមតិនៃបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ ដែលបានធ្វើការសម្ភាសន៍នៅក្នុងប្រទេសថៃ និងពង្រាងរបាយការណ៍
* អ្នកស្រីយុនសា មុនតូយ មន្ត្រីតស៊ូមតិនិងព័ត៌មាននៃបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ ដែលបានជួយក្នុងការវិភាគទិន្នន័យនៃលទ្ធផលសម្ភាសន៍
* កញ្ញាម៉ារី ស្លេធីរី អ្នកស្ម័គ្រចិត្តនៃបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ ដែលបានជួយក្នុងការសរសេរពង្រាងរបាយការណ៍
* អ្នកស្រីរ៉ីកូ ហារីម៉ា អ្នកសម្របសម្រួលថ្នាក់តំបន់នៃបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ សម្រាប់ការសម្របសម្រួលការស្រាវជ្រាវនេះ និងពិនិត្យកែសម្រួលរបាយការណ៍
* ខេស៊ី ម៉ាក់ខាធី អ្នកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលពលករអាស៊ី សម្រាប់ការងារស្រាវជ្រាវក្នុងការជួយដល់របាយការណ៍នេះ
* ហ្គាប្រ៊ីយ៉ែល ឃីតធិស អ្នកស្ម័គ្រចិត្តរបស់បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ ក្នុងការពិនិត្យកែតម្រូវរបាយការណ៍

សូមថ្លែងអំណរគុណផងដែរ ដល់អ្នកដែលមិនបានរៀបរាប់ខាងលើ ដែលបានចូលរួមជាពេលវេលាជំនាញនិងការចង្អុលទិសដល់គម្រោងនេះ។

ជាចុងក្រោយ យើងខ្ញុំសូមអរគុណចំពោះ ដែលបានគាំទ្រដល់ការបោះពុម្ពនេះ និងដែលបានបន្តការគាំទ្រដល់បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ។

# អក្សរកាត់

| | |
|---|---|
| ADHOC | សមាគមសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) |
| CMHI | ការធានារ៉ាប់រងសុខភាពពលករដែលត្រូវតែមាន |
| CWCC | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| CWPD | សមាគមននារីកម្ពុជាដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍ |
| FAR | មូលនិធិហ្វារ |
| FCRCW | មជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ការវិលត្រលប់របស់ពលករកម្ពុជា |
| IOM | អង្គការអន្តរជាតិស្តីពីទេសន្តរប្រវេសន៍ |
| ISOC | ទីបញ្ជាការប្រតិបត្តិការសន្តិសុខផ្ទៃក្នុង |
| LSCW | អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី |
| MAP | កម្មវិធីជំនួយពលករទេសន្តរប្រវេសន៍ |
| MMN | បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ |
| MOLVT | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOU | អនុស្សរណៈនៃការយោគយល់គ្នា |
| NCPO | ក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ |
| NV | ការពិសោធន៍សញ្ជាតិ |
| OSSC | មជ្ឈមណ្ឌលច្រកចេញចូលតែមួយ |
| PIBICS | ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបុគ្គលនិងអន្តោប្រវេសន៍ក្នុងបញ្ជីខ្មៅ |
| SBEZ | តំបន់សេដ្ឋកិច្ចព្រំដែនពិសេស |
| US | សហរដ្ឋអាមេរិក |

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ........ I
**អក្សរកាត់** ........ II
**សេចក្តីសង្ខេបប្រតិបត្តិ** ........ ៦
**ផែនទីប្រទេសថៃ និងប្រទេសកម្ពុជា** ........ ១២
**១. គោលបំណងនិងវិធីសាស្រ្ត** ........ ១៣
**២. សវតារ** ........ ១៧
២.១ ស្ថានភាពទូទៅនៃគោលនយោបាយថៃស្តីពីពលករពីកម្ពុជា មីយ៉ាន់ម៉ា/ភូមា និងឡាវ មុនពេលបង្កើតក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ នៅក្នុងប្រទេសថៃ ........ ១៧
២.២ ការផ្តួចផ្តើមគោលនយោបាយឆ្លើយតបចំពោះទេសន្តរប្រវេសន៍ដោយយោធាថៃ បន្ទាប់ពីរដ្ឋប្រហារនៅប្រទេសថៃ ........ ១៨
**៣. ការឆ្លុះបញ្ចាំងពីលំហូរចេញនៃពលករកម្ពុជាក្នុងខែមិថុនា ឆ្នាំ២០១៤** ........ ២០
៣.១ ស្ថានភាពទូទៅនៃព្រឹត្តិការ បង្ក្រាប ការភិតភ័យ ស្លន់ស្លោ និងចាកចេញពីប្រទេសថៃ ២០
៣.២ សវតារនៃពលករដែលបានត្រលប់ទៅប្រទេសកម្ពុជាវិញ ........ ២៣
៣.៣ ពួកគេបានចាកចេញពីប្រទេសថៃដោយមូលហេតុអ្វី និងដោយរបៀបណា? ........ ២៤
៣.៤ តើការចាកចេញភ្លាមៗ បានប៉ះពាល់យ៉ាងណាខ្លះដល់ពលករនិងក្រុមគ្រួសារ ........ ២៤
៣.៥ តើពលករដែលវិលត្រលប់បានដោះស្រាយចំពោះរូបពួកគេដោយរបៀបណា? ........ ២៥
៣.៦ តើរដ្ឋាភិបាលកម្ពុជាបានឆ្លើយតបចំពោះការវិលត្រលប់ភ្លាមៗនៃប្រជាជនកម្ពុជា ដោយរបៀបណាខ្លះ? ........ ២៦
៣.៧ តើនិយោជកនិងអ្នកជំនួញប្រតិកម្មយ៉ាងណាខ្លះ? ........ ២៩
៣.៨ ការឆ្លុះបញ្ចាំងដោយពលករកម្ពុជាដែលវិលត្រលប់ ក្តីសង្ឃឹមទៅអនាគត និងការឆ្លុះបញ្ចាំងពីដំណើរការទេសន្តរប្រវេសន៍ ........ ៣០
៣.៩ អនុសាសន៍នៃពលករកម្ពុជាដែលវិលត្រលប់ ........ ៣០
**៤. ពលរទេសន្តរប្រវេសន៍ទៅហើយវិលវិញៈ ទស្សនៈវិស័យពីប្រទេសថៃ** ........ ៣២
៤.១ គោលនយោបាយឆ្លើយតបទៅលំហូរពលករកម្ពុជា មកពីប្រទេសថៃ ........ ៣២
៤.២ តើមានយន្តការអ្វីខ្លះសម្រាប់ពលករ ក្នុងការធ្វើទេសន្តរប្រវេសន៍ទៅថៃក្នុងពេលបច្ចុប្បន្ននេះ? ........ ៣៧

ទេសន្តរប្រវេសន៍តាមរយៈទីភ្នាក់ងារជ្រើសរើសពលករ ដែលជាដំណើរការមួយ
បង្កើតឡើងអនុលោមតាមអនុសារណៈនៃការយោគយល់គ្នា .............................. ៣៧
មជ្ឈមណ្ឌលច្រកចេញចូលតែមួយសម្រាប់ការចុះឈ្មោះពលករទេសន្តរប្រវេសន៍
នៅក្នុងប្រទេសថៃ.......................................................................................... ៣៨
មជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ការវិលត្រលប់របស់ពលករកម្ពុជា .............. ៤០
មជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងប្រទេសកម្ពុជា ................................... ៤២
៤.៣ ទស្សនៈនៃពលករទេសន្តរប្រវេសន៍វិលត្រលប់ទៅប្រទេសថៃ .............................. ៤៣
**៥. ការឆ្លុះបញ្ចាំង និងអនុសាសន៍ពីបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ** .................................. ៤៦

# សេចក្តីសង្ខេបប្រតិបត្តិ

## ស្ថានភាពមិនទៀងទាត់នៃពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃ:

ការឆ្លុះបញ្ចាំងពីលំហូរចេញនៃពលករទេសន្តរប្រវេសន៍កម្ពុជានិងមេរៀនបទពិសោធន៍

នៅក្នុងខែមិថុនា ឆ្នាំ២០១៤ ក្នុងពេលដែលប្រព័ន្ធផ្សព្វផ្សាយបានចាប់ផ្តើមធ្វើសេចក្តីរាយការណ៍ អំពីការឃាត់ខ្លួន និងការបញ្ជូនត្រលប់ពលករទេសន្តរប្រវេសន៍នោះ ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាដែលត្រូវបានបញ្ជូន ឬចាកចេញពីប្រទេសថៃមានការកើនឡើងយ៉ាងឆាប់រហ័ស។ នៅក្នុងសភាពនៃបាតុភូតមិនធ្លាប់មានពីមុនមកនេះ ទាំងរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល បានប្រឹងប្រែងឆ្លើយតបទៅតាមតម្រូវការរបស់ក្រុមពលករ ដែលត្រលប់មកកម្ពុជាវិញនោះ។ ជាការប្រមើលពីការវិលត្រលប់ ជាយថាហេតុនៃពលករទាំងនេះទៅកាន់ប្រទេសថៃវិញ រួមផ្សំនិងការសង្ឃឹមថាពួកគេនឹងវិលប្រលប់ទៅវិញតាមប្រព័ន្ធផ្លូវការ ទាំងរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជា បានដាក់ចេញយ៉ាងរហ័សនូវកំណែទម្រង់គោលនយោបាយមួយចំនួន ដើម្បីធ្វើអោយប្រព័ន្ធទេសន្តរប្រវេសន៍ស្របច្បាប់ កាន់តែអាចទទួលបាន។ បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ និងអង្គការដៃគូរបស់ខ្លួនបានជឿជាក់ថាវាជាកិច្ចការសំខាន់ដើម្បីធានាថា ការឆ្លើយតបដ៏ឆាប់រហ័សចំពោះលំហូរចេញ នូវពលករទេសន្តរប្រវេសន៍កម្ពុជាទាំងនេះ ឆ្លុះបញ្ចាំងពីសម្លេងនៃពលករទេសន្តរប្រវេសន៍ ក៏ដូចជាគ្រួសាររបស់ពួកគេ បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ ក៏បានសម្រេចចិត្តរៀបចំជាការសម្ភាសន៍មួយ សម្រាប់គំនិតយល់ឃើញនេះផងដែរ។

ការសម្ភាសន៍បានរៀបចំនៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តកណ្តាល។ ដោយសារការសម្ភាសន៍ធ្វើឡើងក្នុងតំបន់ទាំងនេះ ស្ថានភាពមានការប្រែប្រួលយ៉ាងឆាប់រហ័ស ហើយចំនួនដ៏ច្រើនលើសលុបនៃពលករដែលវិលត្រលប់ បានចាប់ផ្តើមវិលទៅប្រទេសថៃវិញ។ ទោះជាយ៉ាងណា បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ បានសម្រេចចិត្តក្នុងការកែសម្រួល ផែនការ របស់ខ្លួនក្នុងគោលបំណង ទទួលបាននូវការយល់ដឹងគ្រប់ជ្រុងជ្រោយពីស្ថានភាព និងបានចាត់ចែងការសម្ភាសន៍ចំពោះអ្នកដែលបានវិលត្រលប់ទៅប្រទេសថៃវិញ រួមទាំងនិយោជករបស់ពួកគេ និងមន្ត្រីរដ្ឋាភិបាលមូលដ្ឋានក្នុងប្រទេសថៃ ផងដែរ។ ជាលទ្ធផល មានពលករទេសន្តរប្រវេសន៍កម្ពុជា ចំនួន៦៧នាក់ ដែលទើបនឹងត្រលប់ទៅកម្ពុជាវិញត្រូវបានសម្ភាសន៍។ គ្រួសាររបស់ពលករកម្ពុជាដែលវិលត្រលប់ទៅវិញចំនួន៣៨នាក់ ក៏ត្រូវបានសម្ភាសន៍ដែរ។ ការសម្ភាសន៍នេះ ក៏បានរៀបចំសម្រាប់ពលករដែលបានវិល ត្រលប់ទៅកាន់ប្រទេសថៃវិញ ចំនួន១៣នាក់។ ជាចុងក្រោយ អ្នកផ្តល់ព័ត៌មានសំខាន់ចំនួន១៨នាក់ ក៏ត្រូវបានសម្ភាសន៍ផងដែរ។ នៅក្នុងប្រទេសកម្ពុជា អ្នកផ្តល់ព័ត៌មានសំខាន់រួមមានមន្ត្រីមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងស្តារនីតិសម្បទា ក៏ដូចជាអភិបាលរងក្រុងប៉ោយប៉ែតផងដែរ។ ចំណែកឯប្រទេសថៃ រួមមានមន្ត្រីមន្ទីរការងារ មន្ត្រីរដ្ឋបាលខេត្ត និងនិយោជករបស់ពលករទេសន្តរប្រវេសន៍។

លំហូរចេញដ៏សន្ធឹកសន្ធាប់នៃពលករកម្ពុជាពីប្រទេសថៃ បានចាប់ផ្តើមភ្លាមៗបន្ទាប់ពីរដ្ឋប្រហារ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ដោយយោធាថៃ ដែលបង្កើតដោយខ្លួនឯងនូវអាជ្ញាធរគ្រប់គ្រងក្នុងទម្រង់នៃ ក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់។ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤ ក្រុមប្រឹក្សានេះ បានចាប់ផ្តើម ការចុះឃាត់ខ្លួននិងបញ្ជូនត្រលប់នូវពលករទេសន្តរប្រវេសន៍ ដែលគ្មានឯកសារចេញពីប្រទេសថៃ។ ចំនួននេះ បានកើនយ៉ាងឆាប់រហ័សពី១៦៣នាក់ បញ្ជូនត្រលប់នៅថ្ងៃទី៣ ខែមិថុនា ទៅ២.៩៩៣នាក់ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤។ ទោះជាយ៉ាងណា រហូតដល់ថ្ងៃទី១១ ខែមិថុនា ក្រុមប្រឹក្សាជាតិបានចេញសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ទាក់ទងនិងគោលជំហរខ្លួន ចំពោះពលករទេសន្តរ ប្រវេសន៍ដែលគ្មានឯកសារនៅក្នុងប្រទេសថៃ។ អ្នកនាំពាក្យយោធាថៃ អ្នកស្រីស៊ីរីចាន់ង៉ាថុង បានថ្លែងថា "ចាប់ពីពេលនេះតទៅពលករខុសច្បាប់ណាម្នាក់ដែលរកឃើញក្នុងប្រទេសថៃនឹងត្រូវបានឃាត់ខ្លួននិងបញ្ជូនត្រលប់"។ អ្នកស្រី បញ្ជាក់ទៀតថារដ្ឋាភិបាលយោធា ពិនិត្យឃើញថា "ពលករខុសច្បាប់គឺជាការគំរាមកំហែង ដោយសារតែមានពួកគេជាច្រើន ហើយគ្មានវិធានការណ៍ច្បាស់លាស់ក្នុងការដោះស្រាយបញ្ហានេះ ដែលអាចនឹងនាំទៅរកបញ្ហាសង្គម"។ សេចក្តីថ្លែងការណ៍នេះ រួមផ្សំជាមួយការបញ្ជូនត្រលប់ដ៏ច្រើនលើសលុប បានធ្វើអោយពុះកញ្ជ្រោលនូវភាពភ័យខ្លាច នៃការចុះបង្ក្រាប ក្នុងចំណោមពលករទេសន្តរ ប្រវេសន៍ទៀងទាត់និងមិនទៀងទាត់ក្នុងប្រទេសថៃ ហើយបណ្តាលអោយមានការចាកចេញដ៏ច្រើនសន្ធឹកសន្ធាប់នៃពលករទេសន្តរប្រវេសន៍កម្ពុជា។

ចំនួនពលករកម្ពុជាចាកចេញពីប្រទេសថៃតាមរយៈការបញ្ជូនត្រលប់និងការចាកចេញដោយខ្លួនឯង មានការកើនឡើងជាដំណាក់ៗ។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ចំនួនពលករ១៦.៥០៨នាក់ ត្រូវបានបញ្ជូនត្រលប់។ ក្នុងពេលប្រទេសថៃកំពុងតែបញ្ជូនត្រលប់យ៉ាងសកម្ម នូវពលករទេសន្តរប្រវេសន៍នោះ ប្រទេសថៃបានចេញសេចក្តីថ្លែងការណ៍ថា ខ្លួនមិនបានធ្វើរឿងបែបនោះទេ។ ជាឧទាហរណ៍ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ លោកឧត្តមសេនីយ៍ចាន់អូចា បានបដិសេធថាយោធានឹងបង្ក្រាបពលករទេសន្តរប្រវេសន៍គ្មានឯកសារ ក្នុងពេលដែលប្រទេសថៃ "នៅតែត្រូវការពលករគ្មានជំនាញ" ។ អ្នកនាំពាក្យ ក្រសួងការបរទេសថៃ លោកសេក វ៉ាន់ណាមេធី ក៏បដិសេធផងដែរ ដែលថាយោធាកំពុងធ្វើការបង្ក្រាប ប៉ុន្តែបានបញ្ជាក់ថាយោធាកំពុងចាត់ចែង"ការវិលត្រលប់ដោយស្ម័គ្រចិត្ត"។ ដោយមិនគិតអំពីសេចក្តីថ្លែងការណ៍ផ្លូវការ ការបញ្ជូនត្រលប់ពលករនៅតែបន្តជាមួយចំនួនពលករ ៤០.៣៣៩នាក់ ត្រូវបានបញ្ជូនទៅវិញនៅថ្ងៃទី១៣ ខែមិថុនា និង២៦.៧៦៣នាក់នៅថ្ងៃទី១៥ ខែមិថុនា ។ នៅថ្ងៃទី១៥ ខែមិថុនា ផងដែរ អភិបាលខេត្តបន្ទាយមានជ័យ ក្នុងប្រទេសកម្ពុជា បានលើកឡើងថាមានប្រជាជនកម្ពុជាចំនួន១៣៥.០០០នាក់ បានចាកចេញពីប្រទេសថៃថ្មីៗ ដែល២៥.០០០នាក់ក្នុងចំណោមនោះ បានឆ្លងដែននៅថ្ងៃទី១៥ ខែមិថុនា។ គិតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ចំនួនសរុបនៃពលករទេសន្តរប្រវេសន៍កម្ពុជាដែលបានចេញ ឬបានបញ្ជូនត្រលប់មកពីប្រទេសថៃ ក្នុងពេលពីរសប្តាហ៍មុន ត្រូវបានរាយការណ៍ថាមានចំនួន ២២៦.០០០នាក់។

រដ្ឋាភិបាលកម្ពុជាព្យាយាមដើម្បីជួយដល់ជនជាតិរបស់ខ្លួនដែលវិលមកវិញ តាមរយៈផ្តល់ជូននូវមធ្យោបាយដឹកជញ្ជូន ចាប់គិតពីតម្លៃលិខិតឆ្លងដែនដែលបញ្ចុះដល់៤ដុល្លាអាមេរិក និងបានបង្កើតនូវ

មជ្ឈមណ្ឌលច្រកចេញចូលតែមួយ តាមខេត្តដែលជាប់ជាមួយព្រំដែន នៅក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីជួយពលករទេសន្តរប្រវេសន៍កម្ពុជាទទួលបាននូវឯកសារអត្តសញ្ញាណ នៅពេលដែលពួកគេវិលត្រលប់ទៅប្រទេសថៃវិញជាយថាហេតុ។ ស្របពេលជាមួយគ្នានេះដែរ ម្ចាស់អាជីវកម្មនិងនិយោជកនៅក្នុងប្រទេសថៃ ជាពិសេសក្នុងផ្នែកសំណង់ ចម្ការ និងសហគ្រាសជំនួញស្រូវ បានបន្លឺនូវភាពមិនសប្បាយចិត្ត និងបានលើកឡើងថាការចាកចេញនៃកម្លាំងពលកម្មក្រៅប្រព័ន្ធដល់ថ្នាក់នេះបានជះឥទ្ធិពលដល់ការខាតប្រយោជន៍ចំពោះសហគ្រាសរបស់ពួកគេ និងរាលដាលដល់សេដ្ឋកិច្ចប្រទេសថៃ។

បញ្ហានេះបន្តកើតឡើងរហូតដល់ថ្ងៃទី២៥ ខែមិថុនា នៅពេលដែលក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ បានបង្កើតជាជំហ៊ានដ៏រឹងមាំសំដៅដល់ការសម្របសម្រួលដល់ការវិលត្រលប់នៃពលករទេសន្តរប្រវេសន៍កម្ពុជា។ ទាំងនេះយោងតាមសេចក្តីបង្គាប់លេខ ៧០/២៥៥៧ ពាក់ព័ន្ធចំពោះ "វិធានការក្នុងចន្លោះពេល ក្នុងការដោះស្រាយបញ្ហាពលករទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស"។ សេចក្តីបង្គាប់បានផ្សព្វផ្សាយថា មជ្ឈមណ្ឌលសម្របសម្រួល សម្រាប់ការវិលត្រលប់នៃពលករកម្ពុជានឹងត្រូវបានរៀបចំឡើងក្នុងខេត្តចំនួនបួន នៅថ្ងៃបន្ទាប់។ សេចក្តីបង្គាប់ចំនួន៥ ផ្សេងទៀត ត្រូវបានបញ្ចេញដោយក្រុមប្រឹក្សាជាតិ ពាក់ព័ន្ធទៅនិងការបង្កើតនិងបទបញ្ជានៃមជ្ឈមណ្ឌលសម្របសម្រួលនិងមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ពេញផ្ទៃប្រទេសនៅចន្លោះពីថ្ងៃទី៧ ខែកក្កដា ដល់ថ្ងៃទី២១ ខែកក្កដា។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយ ត្រូវបានបង្កើតតាមខេត្តនីមួយៗ ហើយប្រតិបត្តិករផ្នែកនេសាទ តម្រូវអោយចុះឈ្មោះពលករទេសន្តរប្រវេសន៍របស់ពួកគេនៅលើដីគោក។ យោងទៅតាមការិយាល័យរដ្ឋបាលពលករបរទេសនៃក្រសួងការងារ មកទល់ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ចំនួនសរុបនៃពលករដែលបានចុះឈ្មោះមានរហូតដល់ ១.៤៩៣.៧៨១នាក់។ ក្នុងចំណោមនោះ ការបែងចែកតាមជនជាតិ មានកម្ពុជា ៦៨១.៥៧១នាក់ មីយ៉ាន់ម៉ា ៦០០.៨១៦នាក់ និងលាវ ២១១.៣៩៤នាក់។

គោលនយោបាយចុះឈ្មោះអន្តោប្រវេសន៍ថ្មី ដែលបានអនុម័តដោយក្រុមប្រឹក្សាជាតិ បានបំពេញបន្ថែមទៅលើនីតិវិធីអន្តោប្រវេសន៍ដែលមានស្រាប់តាំងពីឆ្នាំ២០០៧ ដែលត្រូវបានធ្វើនិយ័តកម្មតាមរយៈអនុសារណៈនៃការយោគយល់គ្នាជាច្រើន ដែលប្រទេសថៃមានជាមួយប្រទេសកម្ពុជា ប្រទេសឡាវ និងសហភាពមីយ៉ាន់ម៉ា។ ដំណើការទេសន្តរប្រវេសន៍តាមរយៈ អនុសារណៈនៃការយោយល់គ្នា មានតម្លៃខ្ពស់និងស្មុគស្មាញ ហើយអាស្រ័យលើពលករទេសន្តរប្រវេសន៍ ដែលកំពុងមានការលំបាកស្រាប់ក្នុងការធ្វើឯកសារ និងការទំនាក់ទំនងផ្សេងៗទៅហើយនោះ។ ដំណើរការនេះជាទូទៅតម្រូវអោយពលករចូលទៅរកសេវាពីទីភ្នាក់ងារជ្រើសរើសពលករ ដែលត្រូវប្រើពេលជាអប្បបរិមា ៥៣ថ្ងៃ ក្នុងការធ្វើឯកសារចប់សព្វគ្រប់។

បន្ថែមទៅលើដំណើរការទេសន្តរប្រវេសន៍តាមអនុសារណៈនៃការយោគយល់គ្នា ក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ បានបង្កើតនូវយន្តការចុះឈ្មោះទេសន្តរប្រវេសន៍ពីរផ្សេងទៀត តាមរយៈការផ្តល់ជូននូវសេចក្តីបង្គាប់ជាជម្រើស ស្តីពីការចុះឈ្មោះពលករទេសន្តរប្រវេសន៍។ យន្តការ

ថ្មីដំបូងគេ គឺមជ្ឈមណ្ឌលសម្របសម្រួល។ ការបើកមជ្ឈមណ្ឌលនេះ មានបំណងបើកជាលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ គឺសម្រាប់តែជនជាតិកម្ពុជាដែលមានបំណងត្រលប់ទៅប្រទេសថៃវិញ ដើម្បីធ្វើការងារតាមរយៈ មជ្ឈមណ្ឌលទាំងនេះ ដែលត្រូវបានរំពឹងថានឹងចុះឈ្មោះត្រឹមថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤។ បន្ទាប់មកទៀត ពលករត្រូវតែធ្វើទេសន្តរប្រវេសន៍ ទៅតាមវិធីត្រឹមត្រូវជាធម្មតា។ មជ្ឈមណ្ឌលទាំងនេះ បានផ្តល់ជូននូវការអនុញ្ញាតិការងាររយៈពេល៦០ថ្ងៃ ដល់ពលករទេសន្តរប្រវេសន៍ណា ដែលមានលិខិតឆ្លងដែន ឬប័ណ្ណព្រំដែន។

យន្តការថ្មីទីពីរបង្កើតឡើងដោយក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ គឺមជ្ឈមណ្ឌលច្រកចេញចូលតែមួយ។ មជ្ឈមណ្ឌលនេះ ត្រូវបានបង្កើតដើម្បីផ្តល់សេវាដល់ក្រុមពលករទេសន្តរប្រវេសន៍បីប្រភេទនិងមនុស្សនៅក្នុងបន្ទុករបស់ពួកគេដែលមានអាយុក្រោម១៥ឆ្នាំ៖ ១)សម្រាប់ពលករដែលបានចុះឈ្មោះពីមុនក្រោមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៣ និងសុពលភាពឯកសារអនុញ្ញាតិការងាររបស់ពួកគេត្រូវផុតនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ ២)សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលបានចុះឈ្មោះរួចហើយនៅមជ្ឈមណ្ឌលសម្របសម្រួល និង ៣)សម្រាប់ពលករទេសន្តរប្រវេសន៍ដែលគ្មានឯកសារមកពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ កំពុងនៅក្នុងប្រទេសថៃរួចហើយ។ ពលករដែលបានចុះឈ្មោះ ត្រូវបានអនុញ្ញាតិអោយធ្វើការរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ និងសម្រាប់តែធ្វើការអោយនិយោជកដែលបានធានាពួកគេនៅកន្លែងធ្វើការ ដូចដែលបានបញ្ជាក់ នៅលើឯកសារអនុញ្ញាតអោយធ្វើការ។

ប្រទេសកម្ពុជាក៏បានព្យាយាមក្នុងការចាត់ចែងដំណើរការទេសន្តរប្រវេសន៍តាមអនុសារណៈនៃការយោគយល់គ្នាដែរ តាមរយៈការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងប្រទេសកម្ពុជា។ ទិសដៅជាបឋមរបស់មជ្ឈមណ្ឌល គឺសម្របសម្រួលដល់ដំណើរការស្នើសុំលិខិតឆ្លងដែន សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាពីរប្រភេទ៖ ១)ពលករដែលនៅក្នុងប្រទេសកម្ពុជាដែលមានបំណងធ្វើទេសន្តរប្រវេសន៍តាមរយៈដំណើរការនៃអនុសារណៈនៃការយោគយល់គ្នា និង ២)ពលករទេសន្តរប្រវេសន៍កម្ពុជាដែលកំពុងនៅក្នុងប្រទេសថៃ ប៉ុន្តែសម្រាប់អ្នកណាដែលមានបំណងទទួលបានឯកសារអត្តសញ្ញាណជាតិ ដើម្បីអនុញ្ញាតិអោយពួកគេក្លាយជាពលករមានឯកសារត្រឹមត្រូវ។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយរបស់កម្ពុជា អនុញ្ញាតិអោយជនជាតិកម្ពុជាអាចបំពេញបែបបទតាមតម្រូវការតាមដំណើរការនៃអនុសារណៈនៃការយោគយល់គ្នា បានកាន់តែឆាប់រហ័ស ដោយពលករខ្លួនឯងផ្ទាល់ ឬក៏តាមរយៈទីភ្នាក់ងារជ្រើសរើសពលករ។

ដោយផ្អែកលើពលករទេសន្តរប្រវេសន៍កម្ពុជា៦៧នាក់ ដែលបានវិលត្រលប់ ដែលក្រុមអ្នកស្រាវជ្រាវរបស់បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ បានសម្ភាសន៍នៅក្នុងប្រទេសកម្ពុជានោះ និន្នាការដូចតទៅនេះត្រូវបានរកឃើញ។ ភាគច្រើននៃពលករវិលត្រលប់ទៅកម្ពុជាដែលបានសម្ភាសន៍ បានថ្លែងថាពួកគេមិនត្រូវបានបង្ខំអោយចេញពីប្រទេសថៃដោយសំអាងលើការឃាត់ខ្លួននិងបញ្ជូនត្រលប់នោះទេ ប៉ុន្តែពួកគេបានវិលត្រលប់ទៅកម្ពុជាវិញ ដោយសារតែពួកគេបានឮស្វរថាអាជ្ញាធរបានកំពុងតែបង្ក្រាបទៅលើពលករទេសន្តរប្រវេសន៍ដែលគ្មានឯកសារ ដូច្នេះហើយពួកគេមានការភ័យខ្លាច និង

បានសម្រេចចិត្តចាកចេញ។ ការវិលត្រលប់ភ្លាមៗនេះ បានបណ្តាលអោយមានឧបសគ្គហិរញ្ញវត្ថុចំពោះពលករជាច្រើន ដោយសារថាដើម្បីចំណាយលើការចាកចេញរបស់ពួកគេ ពលករជាច្រើនត្រូវខ្ចីលុយគេ និងបានបង្កើតទៅជាបំណុលហិរញ្ញវត្ថុ។ លើសពីនេះទៀត ច្រើនជាងពាក់កណ្តាលនៃអ្នកផ្តល់ការសម្ភាសន៍បានថ្លែងថាពួកគេត្រូវការជំនួយហិរញ្ញវត្ថុ។ ដោយសារតែតម្រូវការហិរញ្ញវត្ថុនោះ ពលករវិលត្រលប់៨០,៦%និយាយថាពួកគាត់ចង់ធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃវិញម្តងទៀត និង៥១,៨% មានគម្រោងការរួចហើយក្នុងការធ្វើទេសន្តរប្រវេសន៍ទៅថៃម្តងទៀត។

ក្នុងគោលបំណងយល់ដឹង ពីរបៀបដែលពលករទេសន្តរប្រវេសន៍ វិលត្រលប់ទៅប្រទេសថៃវិញ បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ បានធ្វើការសម្ភាសន៍នៅក្នុងប្រទេសថៃ ជាមួយនិងពលករទេសន្តរប្រវេសន៍កម្ពុជាចំនួន១៣នាក់ ដែលធ្លាប់បានគេចពីប្រទេសថៃក្នុងកំឡុងពេលលំហូរចេញដ៏ច្រើននៃពលករកម្ពុជា ប៉ុន្តែពេលនេះពួកគេបានវិលត្រលប់ទៅថៃវិញហើយ។ អាស្រ័យលើចម្លើយរបស់អ្នកផ្តល់សម្ភាសន៍ចំនួន ៩៦,២% ឆ្លើយថាហេតុផលចំបងបំផុតដែលពួកគាត់បាន ជ្រើសរើសការវិលទៅប្រទេសថៃវិញ គឺដោយសារតែកង្វះឱកាសការងារក្នុងប្រទេសកម្ពុជា ។ មូលហេតុផ្សេងៗទៀតរួមមាន និយោជករបស់ពួកគាត់នៅក្នុងប្រទេសថៃសុំអោយពួកគាត់ត្រលប់មកធ្វើការវិញ ឬដោយសារពួកគាត់បានឮសូរថាក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់បានបើកមជ្ឈមណ្ឌលចុះឈ្មោះពលករទេសន្តរប្រវេសន៍។ អត្រាខ្ពស់បំផុត គឺ៣៨,៥% នៃអ្នកផ្តល់ការសម្ភាសន៍ មិនបានចូលប្រទេសថៃតាមរយៈដំណើរការផ្លូវការណាមួយទេ។ ពួកគាត់បានថ្លែងថា ពួកគាត់រើសយករបៀបចូលប្រទេសថៃបែបនេះ ដោយសារតែពួកគាត់មិនមានឯកសារធ្វើដំណើរ តែពួកគាត់បានស្គាល់អ្នកនាំផ្លូវ ដែលធ្វើអោយពួកគាត់មានសុវត្ថិភាពនិងអស់ប្រាក់តិចជាងការធ្វើលិខិតឆ្លងដែន។ ចំណែកឯ ៣០,៨% ផ្សេងទៀត បានឆ្លងព្រំដែនតាមវិធីមិនផ្លូវការ រួចហើយទើបទៅកាន់ មជ្ឈមណ្ឌលសម្របសម្រួល។ ហេតុផលសាមញ្ញចំពោះការធ្វើបែបនេះ ក៏ដោយសារតែពលករទទួលស្គាល់ថា នេះគឺជាវិធីមួយ ដែលនឹងធ្វើអោយពួកគាត់អាចវិលទៅធ្វើការវិញដោយឆាប់រហ័ស។ ទោះបីជាអ្នកផ្តល់ការសម្ភាសន៍ជាច្រើន មិនបានវិលចូលទៅប្រទេសថៃវិញតាមបណ្តាញត្រឹមត្រូវក៏ដោយ ៩២,៣% បាននិយាយថាពួកគាត់មានគម្រោងចូលរួមក្នុងដំណើរការចុះឈ្មោះក្នុងពេលបច្ចុប្បន្ននេះ។

បន្ទាប់ពីឆ្លុះបញ្ចាំងលើការសម្ភាសន៍ជាមួយពលករទេសន្តរប្រវេសន៍ គ្រួសាររបស់ពួកគាត់ មន្ត្រីសំខាន់ៗ រួចមក បណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ បានចងក្រងជាអនុសាសន៍ ដាក់ជូនទៅរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលថៃ និងអាស៊ាន ដែលអនុសាសន៍មួយចំនួនក្នុងចំណោមនោះ ត្រូវបានជ្រើសរើសមកបង្ហាញដូចខាងក្រោម។

## សម្រាប់រដ្ឋាភិបាលកម្ពុជា ដើម្បី៖

- ពិនិត្យឡើងវិញនូវគោលនយោបាយថ្នាក់ជាតិដែលមាន ដើម្បីបង្កើតការងារសមរម្យដោយមានប្រាក់ឈ្នួលចិញ្ចឹមជីវិតបានសមរម្យ និងធ្វើអោយប្រសើរឡើងនូវស្តង់ដាររស់នៅ សម្រាប់ប្រជាជនរបស់ខ្លួន។

## សម្រាប់រដ្ឋាភិបាលថៃ ដើម្បី៖

- រៀបចំការវាយតម្លៃអោយបានជិតដល់មួយ អំពីផលប៉ះពាល់នៃគោលនយោបាយ អន្តោប្រវេសន៍របស់ខ្លួន។
- ធានាថាពលករទាំងអស់ ទទួលបាននូវប្រាក់ឈ្នួលអប្បបរិមាដែលពួកគេត្រូវទទួលបាន និងធ្វើកិច្ចការឆ្ពោះទៅរកការផ្តល់នូវប្រាក់ឈ្នួលចិញ្ចឹមជីវិតសមរម្យសម្រាប់ទាំងអស់គ្នា។ និង
- ពិនិត្យឡើងវិញនូវគោលនយោបាយ ដែលបង្កើនបញ្ហាប្រឈមសម្រាប់ ពលករទេសន្តរប្រវេសន៍ ដែលនឹងក្លាយទៅជាពលករគ្មានឯកសារ ហើយដែលនឹងធ្វើអោយពួកគេប្រឈមទៅនិងការឃាត់ខ្លួននិងការបញ្ជូនត្រលប់។

## សម្រាប់រដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជា ដើម្បី៖

- ពិនិត្យឡើងវិញនូវយន្តការទេសន្តរប្រវេសន៍បច្ចុប្បន្ន ក្នុងគោលបំណងធ្វើអោយមាន លក្ខណៈកាន់តែងាយស្រួល កាន់តែឆាប់រហ័ស កាន់តែតម្លៃទាប និងកាន់តែងាយស្រួលទទួលបានសម្រាប់ពលករធម្មតា។

## សម្រាប់អាស៊ាន ដើម្បី៖

- បញ្ជាក់អោយច្បាស់ពីទំហំនៃ សេចក្តីថ្លែងការអាស៊ានស្តីពីការការពារនិងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និងជម្រុញអោយរដ្ឋសមាជិក ធ្វើការពិនិត្យឡើងវិញនូវ គោលនយោបាយទេសន្តរប្រវេសន៍រៀងៗខ្លួន ដើម្បីធ្វើអោយប្រសើរឡើងនូវជីវិតនៃពលករទេសន្តរប្រវេសន៍ នៅតាមសហគ្រាសនានា។

ពលករទេសន្តរប្រវេសន៍ គឺជាឆ្អឹងខ្នងនៃសង្គមនិងសេដ្ឋកិច្ចនៅក្នុងតំបន់ ហើយការធានានូវសុវត្ថិភាពនិងភាពថ្លៃថ្នូររបស់ពួកគេ គឺជាប្រការសំខាន់នៅក្នុងការអភិវឌ្ឍន៍ និងសុខមាលភាពនៅក្នុងតំបន់។

# ផែនទីនៃប្រទេសថៃ និងប្រទេសកម្ពុជា






## ១.គោលបំណង និង វិធីសាស្ត្រ

នៅដើមខែមិថុនា ឆ្នាំ២០១៤ ប្រព័ន្ធផ្សព្វផ្សាយបានចាប់ផ្តើមរាយការណ៍ពីការចាប់និងបញ្ជូនត្រលប់នូវពលករទេសន្តរប្រវេសន៍ពីប្រទេសថៃ ហើយចំនួនពលករដែលបញ្ជូនត្រលប់ ឬចាកចេញពីប្រទេសដោយសារភាពភ័យខ្លាច ចាប់ផ្តើមច្រើនឡើងៗយ៉ាងឆាប់រហ័ស។ ចំនួនពលករកម្ពុជាដែលបញ្ជូនត្រលប់ ឬវិលមកវិលត្រូវបានរាយការណ៍ថាកើនដល់ជាង ២២០.០០០នាក់ ក្នុងរយៈពេលតែ២សប្តាហ៍ប៉ុណ្ណោះ ដែលនេះគឺជាចលនាដ៏ធំបំផុតនៃមនុស្សក្នុងតំបន់អាស៊ីអាគ្នេយ៍ចាប់តាំងពីទស្សវត្សន៍ទី៧០មក។ ចំពោះមុខនៃបាតុភូតមិនធ្លាប់មានពីមុនមកបែបនេះ ទាំងអង្គភាពរដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាលបានខិតខំឆ្លើយតបតាមតម្រូវការរបស់អ្នកទាំងនោះដែលត្រលប់មកកម្ពុជាវិញភ្លាមៗបែបនេះ និងត្រូវការត្រលប់ទៅលំនៅដ្ឋានដ៏កំសត់របស់ពួកគេនៅតាមខេត្តផ្សេងៗ។ សមាជិកខ្លះនៃបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ បាននៅឯជួរមុខក្នុងការចែកចាយជំនួយបន្ទាន់ដល់អ្នកដែលវិលត្រលប់ទាំងនោះ។ ដោយសារតែបញ្ហានេះត្រូវការអោយមានការឆ្លើយតបអន្តរព្រំដែន សមាជិក MMN ដែលមានមូលដ្ឋាននៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជាបានចែករំលែកព័ត៌មានគ្នាជាប្រចាំ ក្នុងការស្វែងរកដំណោះស្រាយល្អបំផុត។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ MMN បានរៀបចំការប្រជុំបន្ទាន់មួយនៅភ្នំពេញ។ នៅក្នុងការប្រជុំអង្គការដែលជាសមាជិក MMN ដែលបានធ្វើការផ្តល់ជំនួយដល់ពលករវិលត្រលប់នៅតាមបណ្តាខេត្តបានចែករំលែកពីការសង្កេតជំហ៊ានដំបូងរបស់ពួកគេដូចតទៅ៖ ១) ពលករបានត្រលប់មកវិញក្នុងលក្ខណៈចម្រុះ តាមរយៈការចាប់និងការបញ្ជូនត្រលប់។ ពួកគេចាកចេញពីកន្លែងដែលមានការភ័យខ្លាច ឬអាចដោយសារតែនិយោជក ឬក្រុមគ្រួសាររបស់ពួកគេសុំអោយចាកចេញ។ ពលករមួយចំនួនទៅបង្ហាញខ្លួននៅកន្លែងស្ថានីយ៍ប៉ូលីស ដើម្បីទទួលបានការវិលត្រលប់ដោយសុវត្ថិភាពទៅកាន់ព្រំដែន និងបន្ទាប់មកត្រូវបានបញ្ជូនត្រលប់ ក្នុងពេលដែលពលករមួយចំនួនទៀតបានព្យាយាមរកវិធីវិលត្រលប់ដោយខ្លួនឯង ២) ខ្លះទៀតបង់ប្រាក់អោយអ្នកនាំផ្លូវពី២០០០ទៅ៣០០០បាត ដើម្បីនាំពួកគាត់ត្រលប់ ប៉ុន្តែមិនត្រូវបាននាំឆ្លងកាត់ព្រំដែននោះទេ ហើយក្រោយមកត្រូវបានឃាត់ខ្លួននិងបញ្ជូនត្រលប់ដោយមន្ត្រីថៃ ៣) ក្នុងពេលនោះនៅឯច្រកអន្តរជាតិប៉ោយប៉ែត(ខេត្តបន្ទាយមានជ័យ) ឃើញថាមានចំនួនពលករច្រើនជាងគេបំផុតត្រូវបានបញ្ជូនត្រលប់ទៅកម្ពុជា ហើយចំនួនពលករតិចជាងនេះត្រូវបានបញ្ជូនទៅកម្ពុជាតាមច្រកទ្វារអន្តរជាតិនៅក្នុងខេត្តឧត្តរមានជ័យ បាត់ដំបង ប៉ៃលិននិងកោះកុង ៤) បន្ទាប់ពីឆ្លងកាត់ព្រំដែន ពលករភាគច្រើនបំផុតត្រូវត្រលប់ទៅស្រុកកំណើត។ CWPD បានកត់សម្គាល់ថាយ៉ាងតិចមានពលករ១០.០០០នាក់ បានវិលត្រលប់ទៅខេត្តព្រៃវែងតែមួយ។

ការសង្កេតជាជំហ៊ានដំបូងដោយអង្គការជាសមាជិករបស់ MMN បានកំណត់ពីតម្រូវការក្នុងការស៊ើបសួរជាបន្តទៀតតាមរយៈការសម្ភាសន៍ជាមួយពលករ ដើម្បីរកអោយឃើញពីរបៀបដែលបញ្ហាត្រូវបានរីករាលដាល។ បញ្ហាដែលកំណត់ឃើញរួមមាន៖ ១)ប្រាក់ឈ្នួលដែលមិនទាន់បានបង់ ២)ទីជម្រក ៣)អាហារ ៤)ការខាតបង់ផ្នែកជីវភាព (ប៉ះពាល់ដល់ពលករវិលត្រលប់ផងនិងសមាជិកគ្រួសាររបស់ពួកគេផង) ៥)កង្វះខាតនៃការបណ្តុះបណ្តាលជំនាញ (ពលករវិលត្រលប់ជាច្រើននាក់ គ្មានជំនាញដែលចាំបាច់សម្រាប់ទីផ្សារការងារបច្ចុប្បន្ននៅកម្ពុជា) ៦)បំណុលៈ ពលករភាគច្រើនបានខ្ចីលុយគេហើយបានលក់ដីធ្លីនិងទ្រព្យសម្បត្តិផ្សេងៗទៀតដើម្បីបង់ទៅអោយអ្នកនាំផ្លូវ ក្នុងការជួយពួកគាត់ធ្វើទេសន្តរប្រវេសន៍ ឬនាំពួកគាត់ទៅកាន់ប្រទេសថៃ។ ពលករជាច្រើនទទួលបានប្រាក់ឈ្នួលទាបនៅក្នុងប្រទេសថៃ និងមិនមានលទ្ធភាពក្នុងការសងបំណុល ៧)ការថែរក្សាសុខភាព ៨)បញ្ហាប្រឈមនៃការធ្វើទេសន្តរប្រវេសន៍ត្រលប់ទៅប្រទេសថៃវិញដោយស្របច្បាប់ ដែលពលករជាច្រើនមានបំណងវិលទៅថៃវិញ នៅពេលដែលស្ថានភាពវិលទៅរកធម្មតាវិញ។

រដ្ឋាភិបាលកម្ពុជាបានបន្ថយតម្លៃលិខិតឆ្លងដែនទៅត្រឹមតែ ៤ដុល្លាអាមេរិក ដើម្បីជម្រុញអោយជនជាតិរបស់ខ្លួនធ្វើទេសន្តរប្រវេសន៍តាមប្រព័ន្ធផ្លូវការ។ ទោះជាយ៉ាងណា នៅតែមានរបាំងជាច្រើនប្រឈមមុខសម្រាប់ពលករធម្មតា ចំពោះដំណើរការទេសន្តរប្រវេសន៍តាមប្រព័ន្ធផ្លូវការ ដែលមានភាពស្មុគស្មាញនិងចំណាយពេលយូរ។ ពលករជាច្រើន ហាក់ដូចជានៅតែចំណាយលុយទៅអោយអ្នកនាំផ្លូវ/ភ្នាក់ងារ ដើម្បីធ្វើទេសន្តរប្រវេសន៍មិនផ្លូវការ ដែលអាចនាំទៅរកការកើនឡើងនូវបំណុល។

ក្នុងគោលបំណងយល់ដឹងអោយកាន់តែច្បាស់ពីបញ្ហា និងការបង្កើតជាអនុសាសន៍ដើម្បីធ្វើអោយប្រសើរឡើងនូវស្ថានភាព MMN បានសម្រេចចិត្តធ្វើការរៀបចំជាការសម្ភាសន៍ជាមួយពលករនិងក្រុមគ្រួសាររបស់ពួកគេ។

ក្រុមការងារបានសម្រេចចិត្តថា អ្នកដែលនឹងត្រូវបានសម្ភាសន៍រួមមាន ពលករកម្ពុជាដែលទើបនិងបានត្រលប់មកវិញ ឬក៏ត្រូវបានបញ្ជូនត្រលប់មកកម្ពុជាវិញ និងគ្រួសាររបស់ពួកគេផងដែរ ដែលការសម្ភាសន៍និងត្រូវធ្វើក្នុងខេត្តបួនផ្សេងគ្នា គឺបន្ទាយមានជ័យ ព្រៃវែង កំពង់ចាម និងកណ្តាល ដោយប្រើកម្រងសំណួរបែបពាក់កណ្តាលស្តង់ដារ។ ក្រុមការងារក៏បានព្រមព្រៀងគ្នាថា អ្នកផ្តល់ព័ត៌មានសំខាន់មួយចំនួន រួមមានមន្ត្រីរដ្ឋាភិបាល នៅក្នុងតំបន់តាមខេត្តទាំងនោះ និងត្រូវសម្ភាសន៍ដែរ។ ការសម្ភាសន៍ក្នុងខេត្តបន្ទាយមានជ័យ ធ្វើដោយអង្គការ CWCC នៅខេត្តព្រៃវែងធ្វើដោយអង្គការ LSCW នៅខេត្តកំពង់ចាមធ្វើដោយ CWPD និងនៅខេត្តកណ្តាលធ្វើដោយសមាគមអាដហុក។

ដោយសារការសម្ភាសន៍ត្រូវបានធ្វើនៅក្នុងតំបន់ទាំងនេះ ស្ថានភាពបានកែប្រែយ៉ាងឆាប់រហ័ស ហើយចំនួនដ៏ច្រើននៃពលករវិលត្រលប់ បានចាប់ផ្តើមទៅកាន់ប្រទេសថៃវិញ។ យ៉ាងណាមិញ MMN បានសម្រេចចិត្តកែសម្រួលឡើងវិញនូវផែនការការងារ ក្នុងគោលបំណងទទួលបាននូវការយល់ដឹងគ្រប់ជ្រុងជ្រោយពីស្ថានភាព និងបានសម្ភាសន៍ជាមួយពលករដែលបានវិលទៅប្រទេសថៃវិញ ហើយក៏សម្ភាសន៍ជាមួយនិយោជកថៃ និងជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិនៅក្នុងប្រទេសថៃ។ ក្នុងប្រទេសថៃ ការសម្ភាសន៍បានធ្វើនៅក្នុងខេត្តរ៉ាក់យ៉ង ខេត្តត្រាត និងខេត្តស្រះកែវ។

ពលករកម្ពុជាចំនួន៦៧នាក់ ដែលបានវិលទៅកម្ពុជាវិញកាលពីពេលថ្មីៗ និងសមាជិកគ្រួសាររបស់ពួកគាត់ចំនួន៣៨នាក់ ត្រូវបានសម្ភាសន៍។ ពលករកម្ពុជាចំនួន១៣នាក់ ដែលបានវិលទៅកម្ពុជាកាលពីពេលថ្មីៗ ហើយបន្តិចក្រោយមកបានវិលមកប្រទេសថៃវិញ ត្រូវបានសម្ភាសន៍ក្នុងប្រទេសថៃ។ ជាចុងក្រោយអ្នកសំខាន់ចំនួន១៨នាក់ នៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍។ នៅក្នុងប្រទេសកម្ពុជាជនសំខាន់ដែលបានសម្ភាសន៍រួមមាន មន្ត្រីមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីមន្ទីរសង្គមកិច្ច អភិបាលរងក្រុងប៉ោយប៉ែត មេភូមិ និងមេឃុំ។ នៅក្នុងប្រទេសថៃ ជនសំខាន់ដែលបានសម្ភាសន៍រួមមានមន្ត្រីមន្ទីរការងារ មន្ត្រីរដ្ឋាបាលសាលាខេត្ត មន្ត្រីសុខាភិបាលខេត្ត និងនិយោជកនៃពលករ។ ការសម្ភាសន៍ និងបកប្រែដោយក្រុមអ្នកស្រាវជ្រាវរបស់ MMN។

នៅថ្ងៃទី១១ និង១២ ខែកញ្ញា ឆ្នាំ២០១៤ ដៃគូរគម្រោងដែលបានធ្វើការសម្ភាសន៍ និងតំណាងអង្គការជាសមាជិក MMN នៅក្នុងប្រទេសថៃ បានធ្វើការប្រជុំក្នុងគោលបំណងដូចតទៅ៖

i) ដើម្បីចែករំលែកពីការរកឃើញក្នុងការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសថៃ ទាក់ទងនិងលំហូរពលករកម្ពុជា និងរួមគ្នាវិភាគទិន្នន័យ
ii) ដើម្បីចែករំលែកពីការរកឃើញក្នុងការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសថៃ ពីប្រព័ន្ធ/យន្តការផ្សេងៗទាក់ទងនិងការគ្រប់គ្រងទេសន្តរប្រវេសន៍ ឧ.មជ្ឈមណ្ឌលច្រកចេញចូលតែមួយ និងរួមគ្នាវិភាគពីផលប៉ះពាល់ចំពោះពលករ
iii) ដើម្បីស្វែងយល់ពីបច្ចុប្បន្នភាពនៃគោលនយោបាយថៃ ទាក់ទងទេសន្តរប្រវេសន៍ និងរួមគ្នាវិភាគពីផលវិបាក
iv) ដើម្បីបង្កើតការសង្កេតរួមគ្នារបស់ MMN ពីការរៀនសូត្រពីបទពិសោធន៍នៃលំហូរពលករកម្ពុជា ក៏ដូចជាគោលនយោបាយទេសន្តរប្រវេសន៍បច្ចុប្បន្ន និង
v) ដើម្បីរួមគ្នាបង្កើតអនុសាសន៍

អង្គការដែលបានចូលរួមការប្រជុំ សុទ្ធតែបានធ្វើការយ៉ាងជិតស្និតជាមួយសហគមន៍ពលករ នៅក្នុងទីតាំងជាច្រើន និងបានតាមដានមើលពីការផ្លាស់ប្តូរគោលនយោបាយទេសន្តរប្រវេសន៍ និងផលប៉ះ

ពាល់ចំពោះពលករ ក្នុងប៉ុន្មានឆ្នាំនេះ។ ដូច្នេះ មតិយោបល់ពីអង្គការទាំងនេះ បង្កើននូវជម្រៅនិងភាពទាក់ទងចំពោះឯកសារនេះយ៉ាងខ្លាំង ជាពិសេសនៅក្នុងផ្នែកអនុសាសន៍។

ក្នុងពេលដែលចំនួនពលករដែលបានសម្ភាសន៍ក្នុងគម្រោងនេះ គឺតិចតួច បើប្រៀបធៀបទៅចំនួនសរុបនៃពលករកម្ពុជាដែលបានវិលត្រលប់នៅក្នុងខែមិថុនា បំណងនៃគម្រោងគឺដើម្បីបង្កើតជាការឆ្លុះបង្ហាញពីបទពិសោធន៍ និងការយល់ឃើញរបស់ពលករផ្ទាល់ដែលមាន ចំពោះព្រឹត្តិការដែលកើតឡើងនិងពីគោលនយោបាយទេសន្តរប្រវេសន៍ដែលប៉ះពាល់ដល់ពួកគាត់។ សមាជិកក្រុមអ្នកស្រាវជ្រាវក៏មានការពាក់ពាក់ផងដែរចំពោះការផ្តល់ជំនួយទៅដល់ពលករវិលត្រលប់ ដែលបានកកស្ទះក្រោយពេលឆ្លងដែន ឬត្រូវការចាំបាច់នូវជំនួយបន្ទាន់បន្ទាប់ពីទៅដល់ខេត្តកំណើតរបស់ពួកគេវិញ។ ទាំងនេះជាសមត្ថភាពដែលក្រុមស្រាវជ្រាវ អាចឈានទៅដល់ក្នុងសហគមន៍ និងផ្តល់ការវិភាគរួមគ្នាសម្រាប់របាយការណ៍ចុងក្រោយ។

## ២. សាវតារ

### ២. ១ ការពិនិត្យមើលទៅលើគោលនយោបាយថៃ ចំពោះពលករមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា/ភូមា និងប្រទេសឡាវ មុនពេលការបង្កើតក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ នៅប្រទេសថៃ

ពលករទេសន្តរប្រវេសន៍ដែលគ្មានឯកសារពីប្រទេសជិតខាង ដែលមានកម្ពុជា មីយ៉ាន់ម៉ា និងឡាវ មានការរួមចំណែកយ៉ាងច្រើនដល់សេដ្ឋកិច្ចថៃ ចាប់តាំងពីទស្សវត្សរ៍ទី៨០មកម្ល៉េះ។

ការប្រឹងប្រែងជាដំបូងនៃរដ្ឋាភិបាលថៃដើម្បីដោះស្រាយបញ្ហា គឺនៅក្នុងឆ្នាំ១៩៩២ នៅពេលដែលពលករដែលគ្មានឯកសារមកពីមីយ៉ាន់ម៉ា ត្រូវបានផ្តល់ការអនុញ្ញាតអោយធ្វើការតាមមុខរបរជាក់លាក់មួយចំនួន និងតាមខេត្តដែលបានកំណត់។

នៅឆ្នាំ១៩៩៦ រដ្ឋាភិបាលថៃ បានអនុវត្តកម្មវិធីមួយអនុញ្ញាតអោយនិយោជក អាចដាក់ពាក្យសម្រាប់កូតាពលករទេសន្តរប្រវេសន៍ពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ។ មានពលករប្រមាណជា ៣០០.០០០នាក់ ច្រើនជាងគេបំផុតមកពីមីយ៉ាន់ម៉ា បានចុះឈ្មោះក្នុងកម្មវិធីនេះ ប៉ុន្តែមានការជឿជាក់ថាចំនួនពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃ ដែលមិនមានឯកសារនៅតែមានចំនួនច្រើនណាស់[១]។

ក្នុងខែតុលា ឆ្នាំ២០០២ ខែឧសភា ឆ្នាំ២០០៣ និងខែមិថុនា ឆ្នាំ២០០៣ ប្រទេសថៃបានចុះហត្ថលេខាលើអនុសារណៈនៃការយោគយល់គ្នា ពីកិច្ចសហការក្នុងការធ្វើការងាររបស់ពលករពីប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ា ដោយឡែកៗ។ អនុសារណៈ មានបំណងធ្វើអោយត្រឹមត្រូវតាមច្បាប់នូវទេសន្តរប្រវេសន៍ការងារនៅក្នុងប្រទេសថៃ។

គោលនយោបាយចុះឈ្មោះពលករ ដែលបើកទូលាយបំផុតនៅប្រទេសថៃ គឺនៅឆ្នាំ២០០៤ ដែលពលករអាចចុះឈ្មោះទទួលបាននូវប័ណ្ណសំគាល់ខ្លួនពលករបណ្តោះអាសន្នរយៈពេល១ឆ្នាំ (ថរ៣៨/១) ដោយមិនយកប្រាក់ ហើយមិនពឹងអាស្រ័យលើនិយោជក។ ពលករត្រូវបានអនុញ្ញាតអោយធ្វើការប្តូរថ្មីនូវការអនុញ្ញាតការងារ១ឆ្នាំ និងទិញសេវារ៉ាប់រងសុខភាព។ ឯកសារទាំងនេះផ្តល់ជូននូវពលករនូវភាពជឿជាក់ និងការការងារសិទ្ធិជាក់លាក់មួយចំនួន និងបានផ្តាច់ការពឹងពាក់ទៅលើនិយោកជក សម្រាប់ការទទួលបាននូវភាពស្របច្បាប់នេះ។ សរុបពលករដែលបានចុះឈ្មោះមាន ១.២៨៤.៩២០ ក្នុងនោះ ៧០%មកពីមីយ៉ាន់ម៉ា ១៥%មកពីកម្ពុជា និង១៥%មកពីឡាវ។ ក្នុងចំណោមអ្នកចុះឈ្មោះ ៨៤៩.៥៥២នាក់ បានចុះឈ្មោះសម្រាប់ការអនុញ្ញាតការងារ។ ទោះជាយ៉ាងណាលក្ខណៈនៃពលករទេសន្តរប្រវេសន៍ដែលមានប័ណ្ណសំគាល់ខ្លួនបណ្តោះអាសន្ន និងការអនុញ្ញាតការងារ ត្រូវបានចាត់ទុក

ថាមានភាពស្របច្បាប់តែពាក់កណ្តាល ហើយត្រូវបានចាត់ថ្នាក់ថា "ចូលមិនស្របច្បាប់មកធ្វើការក្នុងពេលរង់ចាំការបញ្ជូនត្រលប់"។ ឆ្នាំបន្ទាប់មកទៀតនៃការចុះឈ្មោះត្រូវបានបិទ ដូច្នេះគឺបានទទួលការអនុញ្ញាតត្រឹមតែផ្លាស់ប្តូរថ្មី ហើយរដ្ឋាភិបាលថៃសារជាថ្មីម្តងទៀតបានអនុវត្តនូវការបង្ក្រាបផ្នែកអន្តោប្រវេសន៍។

ឆ្នាំបន្តបន្ទាប់មកបានឃើញថាមានការផ្លាស់ប្តូរទៅគោលនយោបាយដោយគ្មានភាពច្បាស់លាស់ ឬដែលមានទស្សនវិស័យយូរអង្វែង។ បន្ថែមពីលើនេះទៀត គោលនយោបាយបានកំណត់នូវអ្វីៗដែលធ្លាប់កើតមានពីមុន គឺថាការអនុញ្ញាតការងារផ្សារភ្ជាប់ទៅនិងនិយោជកជាក់លាក់ ហើយដែលពលករមិនត្រូវបានអនុញ្ញាតអោយធ្វើការនៅផ្នែកផ្សេងពីអ្នកដែលពួកគាត់បានចុះឈ្មោះថាបម្រើការជាមួយពីដើមដំបូង។ និយោជិតអាចប្តូរការងារដោយមានការអនុញ្ញាតពីនិយោជក និងមន្ទីរការងារ។ ការផ្លាស់ប្តូរទីតាំងក៏ត្រូវបានកំហិតយ៉ាងម៉ត់ចត់ ហើយដែលពលករត្រូវបានកំណត់ព្រំដែនតែក្នុងតំបន់ដែលពួកគាត់ត្រូវបានចុះឈ្មោះ។

ក្នុងពេលតែមួយ ក្នុងបំណងធ្វើអោយត្រឹមត្រូវតាមច្បាប់ចំពោះពលករ យោងតាមអនុសារណៈនៃការយោគយល់គ្នាដែលបានពោលខាងលើ ប្រទេសថៃបានចាប់ផ្តើមអនុវត្តគ្រោងការណ៍ពិសោធន៍សញ្ជាតិ សម្រាប់ពលករទេសន្តរប្រវេសន៍ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ។ អំឡុងពេលបានបញ្ចប់ការពិសោធន៍សញ្ជាតិ ស្ថានភាពពលករត្រូវបានប្តូរពី"ការចូលខុសច្បាប់ហើយធ្វើការ ក្នុងពេលរង់ចាំការបញ្ជូនត្រលប់" ទៅជា "ការចូលមកដោយស្របច្បាប់"។ ពលករទាំងអស់ដែលចុះឈ្មោះដើម្បីទទួលបាននូវការអនុញ្ញាតការងារ ត្រូវតែចូលតាមដំណើរការពិសោធន៍សញ្ជាតិ។ ការពិសោធន៍សញ្ជាតិសម្រាប់ជនជាតិកម្ពុជានិងលាវ បានចាប់ផ្តើមនៅឆ្នាំ២០០៦ និងសម្រាប់ជនជាតិមីយ៉ាន់ម៉ាបានចាប់ផ្តើមនៅឆ្នាំ២០០៩។ ការជ្រើសរើសថ្មីៗនូវពលករពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ តាមរយៈទីភ្នាក់ងារជ្រើសរើសពលករទើបតែបានបង្កើតថ្មីៗ នៅក្នុងប្រទេសទាំងនេះ ក៏បានចាប់ផ្តើមឡើងដែរ។

ពលករដែលបានបញ្ចប់ការពិសោធន៍សញ្ជាតិ ហើយបានធ្វើអោយស្របច្បាប់នូវស្ថានភាពរបស់ពួកគាត់ដោយពេញលេញ ក៏ដូចជាពលករដែលបានធ្វើទេសន្តរប្រវេសន៍មកប្រទេសថៃតាមទីភ្នាក់ងារជ្រើសរើសពលករយោងទៅតាមដំណើរការអនុសារណៈ ("ពលករតាមអនុសារណៈ") បានទទួលសិទ្ធិក្នុងការចូលរួមកម្មវិធីជាតិផ្នែកសុវត្ថិភាពសង្គម ដែលបានផ្តល់ជូនផលប្រយោជន៍គ្រប់ជ្រុងជ្រោយជាង CMHI ដែលពលករមកប្រទេសថៃពីមុនបានចូលរួមអញ្ចឹងដែរ។

## ២.២ គោលនយោបាយឆ្លើយតបជំហ៊ានដំបូងចំពោះទេសន្តរប្រវេសន៍ដោយយោធាថៃ បន្ទាប់ពីរដ្ឋប្រហារក្នុងប្រទេសថៃ

យោលទៅតាមរដ្ឋប្រហារថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ដោយយោធាថៃ រដ្ឋាភិបាលយោធាបានបង្កើតខ្លួនឯងជាអាជ្ញាធរគ្រប់គ្រងនៅក្នុងទម្រង់ជា ក្រុមប្រឹក្សាជាតិដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់។ ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤ NCPO បានចាប់ផ្តើមចាប់ខ្លួននិងបញ្ជូនត្រលប់ពលករមិនមានឯកសារចេញពីប្រទេសថៃ[i]។ ចំនួនបានចាប់ផ្តើមកើនឡើងយ៉ាងឆាប់រហ័ស ដោយការបញ្ជូនត្រលប់ពលករកម្ពុជា៨០នាក់[ii] និងពលករភូមា១៦៣នាក់[iii] នៅថ្ងៃទី៣ ខែមិថុនា ទៅដល់ ២.៩៩៣នាក់នៅថ្ងៃទី១០ ខែមិថុនា[iv]។

រហូតដល់ថ្ងៃទី១១ ខែមិថុនា ដែលចុងក្រោយ NCPO បានធ្វើការថ្លែងការផ្ទាល់មាត់ចំពោះគោលជំហររបស់ខ្លួនសម្រាប់ពលករមិនមានឯកសារនៅក្នុងប្រទេសថៃ។ អ្នកនាំពាក្យទាហានថៃ សិរិចាន់ ង៉ាចុង បានថ្លែងថា ចាប់ពីចំនុចនេះតទៅមុខ ពលករទេសន្តរប្រវេសន៍ខុសច្បាប់ណាម្នាក់ដែលបានរកឃើញនៅប្រទេសថៃ "និងត្រូវបានចាប់ខ្លួននិងបញ្ជូនត្រលប់"។ អ្នកស្រីបន្ថែមទៀតថា រដ្ឋាភិបាលយោធាមើលឃើញថា "ពលករខុសច្បាប់គឺជាការគំរាមកំហែង ដោយសារតែមានពួកគេច្រើនណាស់ ហើយគ្មានវិធានការច្បាស់លាស់ក្នុងការគ្រប់គ្រង ដែលអាចនាំទៅរកបញ្ហាសង្គម"។ ប៉ុស្តិទូរទស្សន៍របស់រដ្ឋាភិបាលថៃ បានប្រកាសថានេះគឺជាផ្នែកមួយនៃ ប្រតិបត្តិការ "សំអាតបរិយាកាស" បានអនុវត្តឡើងដើម្បីសាងសង្គមជាតិ "រីករាយ"មួយ[ix]។ សេចក្តីថ្លែងការណ៍នេះ ត្រឹមតែបង្កើតភាពភ័យខ្លាចចំពោះការបង្ក្រាបក្នុងចំណោមពលករធម្មតានិងពលករមិនធម្មតាក្នុងប្រទេសថៃ និងញុះញង់អោយមានការចាកចេញដ៏ច្រើនលើសលុបនៃពលករកម្ពុជា។

រូបថតដោយ MMN




*ពលករកម្ពុជាដែលបានបញ្ជូនត្រលប់ មកដល់មណ្ឌលទទួលនៅប៉ោយប៉ែត ប្រទេសកម្ពុជា*

## ៣. ការផ្ទុះបញ្ហារាំងពីលំហូរនៃពលករកម្ពុជានៅក្នុងខែមិថុនា ឆ្នាំ២០១៤

### ៣.១ ការពិនិត្យមើលទៅលើព្រឹត្តិការ ការបង្ក្រាប ភាពភ័យខ្លាច ភាពស្លន់ស្លោ និងការចេញពីប្រទេសថៃ

ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ឧត្តមសេនីយ៍ចាន់អូចា ប្រធាននៃ NCPO បានថ្លែងក្នុងការបកស្រាយតាមទូរទស្សន៍ថា គាត់មានបំណងដឹកនាំអោយទៅមុខនូវការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅព្រំដែន ដើម្បីទប់ស្កាត់ "ពលករខុសច្បាប់ពីការឆ្លងចូលទៅក្នុងខេត្តផ្សេងៗនៃប្រទេសថៃ ដែលដូច្នោះនិងផ្តល់ឪកាសការងារកាន់តែច្រើនដល់ជនជាតិថៃ"[x]។ ការថ្លែងការនេះ បង្កើតជាសម្លេងមួយជាបន្តទៀតដោយការថ្លែងការជាផ្លូវការនិងមិនផ្លូវការទាក់ទងនិងពលករ ដែលនិយាយដដែលៗចំពោះ "បញ្ហាពលករទេសន្តរប្រវេសន៍"[xi] ដែលជាបញ្ហាមួយដែលពួកគេខិតខំដោះស្រាយ។

ការបង្ក្រាបទៅលើពលករដែលមិនមានឯកសារបានចាប់ផ្តើមពីថ្ងៃទី៣ មិថុនា នៅពេលដែលអាជ្ញាធរថៃបានចាប់និងបញ្ជូនត្រលប់ពលករភូមា១៦៣នាក់ ក្នុងការចុះឆ្មក់ចូលនៅបានសុងគ្វី ស្រុកមេសត[xii] កងកំលាំងសន្តិសុខថៃបន្ទាប់មកទៀតបានបិទតំបន់ច្រកឆ្លងកាត់ខុសច្បាប់នៅព្រំដែនភូមា ធ្វើអោយកកស្ទះដល់អ្នកដែលតែងតែចេញចូលដើម្បីធ្វើការនៅប្រទេសថៃ[xiii]។

ចំនួនពលករដែលត្រូវបានបញ្ជូនត្រលប់បានកើនឡើងពី១៣៦នាក់ នៅថ្ងៃទី៥ មិថុនា[xiv] ទៅ២.១៦០នាក់ នៅថ្ងៃទី៩ មិថុនា[xv] យោងតាមស្ថិតិផ្លូវការពីមជ្ឈមណ្ឌលសំចតប៉ោយប៉ែត[xiv]។ ចំនួនផ្លូវការនៃពលករបានបញ្ជូននៅថ្ងៃទី១០ មិថុនា គឺ២.៩៩៣នាក់ (១.៦៣៥ជាបុរស ១.០៥៨ជាស្ត្រី និងកុមារ៣០០នាក់)។ នៅថ្ងៃទី១១ មិថុនា យោងទៅតាមអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវព្រំដែនថៃ យ៉ាងតិចជនជាតិកម្ពុជា១០.០០០នាក់ បានឆ្លងព្រំដែនតាំងពីមានរដ្ឋប្រហារមក ហើយចំនួនគិតថានឹងកើនថែមទៀតស្របតាមសេចក្តីថ្លែងការរបស់ NCPO ក្នុងថ្ងៃតែមួយដែលថា ពលករខុសច្បាប់នឹងត្រូវបានចាប់ខ្លួននិងបញ្ជូនត្រលប់[xvii]។

នៅថ្ងៃទី១១ មិថុនា ផងដែរ មានប៉ូលីសសណ្តាប់ធ្នាប់ថៃជាង១០០នាក់ បានឆ្មក់ចូលកន្លែងប្រមូលផ្តុំពលករភូមានៅខេត្តឈៀងម៉ៃ ជិតវត្តប៉ាប៉ាវ និងបានបង្ខាំងពួកគេក្នុងឡានទ្រុងដែលពេញទៅដោយពលករទេសន្តរប្រវេសន៍[xviii]។ សរុបពលករ ៧.៦៨៦នាក់ ត្រូវបានបញ្ជូនត្រលប់នៅថ្ងៃទី១១មិថុនា។ ថ្ងៃទី១២ មិថុនា យោងតាមការចាប់ខ្លួនពលករមិនមានឯកសារជាង១០០ពីសហគមន៍មូស្លីមនៅស្រុកមេសត វរៈសេនីយ៍នគរបាល ពុងញ៉ាខន បានថ្លែងថាការដកចេញនូវពលករទេសន្តរប្រវេសន៍គឺ "ល្អសម្រាប់សន្តិសុខជាតិ"[xix]។ ថ្ងៃដដែលឃើញថាមានពលករកម្ពុជា ៦០០នាក់ ដែលមានបំណងចង់ចេញពីប្រទេសថៃតាមខេត្តសុរិន្ទ ត្រូវបានចាប់ខ្លួននិងបញ្ជូនត្រលប់ ហើយ១៦.៥០៨នាក់ត្រូវបានបញ្ជូនត្រលប់ជាសរុប។

ក្នុងការឆ្លើយតបទៅនិងការកើនឡើងនូវក្តីបារម្ភពីផ្នែកអាជីវកម្ម អំពីការបាត់បង់កំលាំងការងារ នៅថ្ងៃទី១៣ មិថុនា ឧត្តមសេនីយ៍ចាន់អូចា បានបដិសេធដែលថាទាហ៊ាននឹងបង្ក្រាបទៅលើពលករដែលមិនមានឯកសារ ដោយសារតែប្រទេសថៃ "នៅតែត្រូវការពលករគ្មានជំនាញ"[xx]។ អ្នកនាំពាក្យក្រសួងការងារថៃ សេក វណ្ណាមេធី ក៏បានបដិសេធផងដែរដែលថាយោធាកំពុងធ្វើការបង្ក្រាប ប៉ុន្តែបានបញ្ជាក់ថាយោធាកំពុងសម្របសម្រួលជនជាតិកម្ពុជាដែល "ស្ម័គ្រចិត្ត" វិលទៅវិញ[xxi]។ លោកវណ្ណាមេធីបានបន្តនិយាយថា "អាជ្ញាធរថៃបានដឹងពីសារៈសំខាន់នៃពលករទេសន្តរប្រវេសន៍ពីប្រទេសជិតខាងដែលជួយរុញសេដ្ឋកិច្ចថៃទៅមុខ...។ជាលទ្ធផល យើងចង់ផ្លាស់ប្តូរទម្រង់និងរួមបញ្ចូលនូវប្រព័ន្ធគ្រប់គ្រង ក៏ដូចជាបញ្ចៀសការកេងប្រវ័ញ្ចពីជនរត់ពន្ធ ក្នុងការទទួលបានមួយដើម្បីទប់ស្កាត់ការរំលោភបំពានពលករ និងបញ្ហាអំពើជួញដូរមនុស្ស"[xxii]។

ពលកររាប់សិបពាន់នាក់បានបន្តចាកចេញពីប្រទេសថៃប្រចាំថ្ងៃ ហើយដែលមានចំនួនប្រហែលជា ៩៥.០០០នាក់ គ្រាន់តែក្នុងថ្ងៃទី១៤ មិថុនា។ ក្នុងថ្ងៃជាមួយគ្នា មានពលករកម្ពុជាមិនមានឯកសារ៦នាក់និងអ្នកបើកបរបានស្លាប់ក្នុងគ្រោះថ្នាក់រថយន្តនៅតាមផ្លូវទៅព្រំដែន ដែលធ្វើអោយឧប្បទ្ទវហេតុនេះក្លាយជាការខូចខាតដំបូង ក្នុងការវិលត្រលប់ដ៏គំហុកទៅប្រទេសកម្ពុជា ចាប់តាំងពីរដ្ឋប្រហារយោធា[xxiii]។ ជាងពាក់កណ្តាលនៃពលករដែលវិលទៅកម្ពុជាវិញ គឺស្ត្រីនិងកុមារ ហើយពលករជាច្រើនអត់មានមធ្យោបាយធ្វើដំណើរជាបន្តបន្ទាប់ពីឆ្លងកាត់ព្រំដែន។ ក្រៅពីយានជំនិះ ពួកគាត់លើកពីតម្រូវការកើនឡើងផ្នែកអាហារ ទឹក សុខភាព និងទីជម្រក។

ថ្ងៃទី១៥ មិថុនា ឯកឧត្តមគោស៊ុំ សារឿត អភិបាលខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា បានបង្ហើបថារថយន្តយោធានិងរថយន្តក្រុង ៣០០គ្រឿង បានបញ្ជូរថាំដឹកពលករទៅស្រុកកំណើតវិញដោយមិនគិតសោហ៊ុយ ហើយអាជ្ញាធរមូលដ្ឋាននិងអង្គការមនុស្សធម៌បានផ្តល់ដល់អ្នកវិលមកវិញ នូវអាហារនិងទឹកហូប។ អង្គការ IOM បានប៉ាន់ស្មានថាមានជនជាតិកម្ពុជា ១២០.០០០ បានត្រលប់មកវិញចាប់តាំងពីរដ្ឋប្រហារយោធាថ្ងៃទី២២ ឧសភា។

រូបថតផ្តល់ដោយ CWCC



*ពលករវិលត្រលប់រង់ចាំត្រលប់ទៅផ្ទះវិញ (ប៉ោយប៉ែត កម្ពុជា)*

នៅថ្ងៃទី១៦ មិថុនា សារជាថ្មីម្តងទៀត NCPO បានបដិសេធថាមិនមានគោលនយោបាយ "បោស និង សំអាត" ដែលរុញច្រានពលករបរទេសមិនមានឯកសារចេញពីប្រទេស ប៉ុន្តែបែជានិយាយថា មន្ត្រីរបស់ខ្លួន "និងចុះមើលតំបន់ដែលមានពលករខុសច្បាប់ ដើម្បីសិក្សាពីបញ្ហាពិតប្រាកដដែលមានរហូតមកបង្កមកពីការកង្វះការគ្រប់គ្រងយូរមកហើយចំពោះពលករមកពីក្រៅស្រុក" រួមទាំងពលកម្មកុមារ អំពើជួញដូរមនុស្ស និងអំពើពុករលួយពាក់ព័ន្ធនិងមន្ត្រីនិងភ្នាក់ងារការងារ[xxiv]។ អ្នកនាំពាក្យ NCPO វីនថៃ ស៊ូវ៉ារី បន្តថ្លែងថា "យើងសួរថាអ្នកដែលជួលពលករបរទេស បន្តសកម្មភាពរបស់ពួកគេតាមធម្មតា និងរក្សាសណ្តាប់ធ្នាប់ល្អ"[xxv]។

នៅថ្ងៃទី១៦ មិថុនា អ្នកជំនួញថៃ បានចាប់ផ្តើមបើកចំហរជាសាធារណៈពីភាពភ័យខ្លាចកង្វះពលកម្ម និង ផលប៉ះពាល់នៃការខូចប្រយោជន៍ដល់សេដ្ឋកិច្ចថៃ ដែលអាចបណ្តាលមកពីការទៅបាត់នៃពលករទេសន្តរប្រវេសន៍។ ប្រាសើត តៃឌុលឡាយ៉ាសាទីត ជាប្រធាននៃសមាគមខុនដូថៃ បានទស្សទាយថាកង្វះពលកម្មនឹងពន្យឺតការបើកគម្រោង និងការសង់លំនៅដ្ឋាន។ អតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ធីរ៉ាឆៃ ភូវ៉ាណាត់ណារ៉ានូបាឡា ក៏បានព្រមានផងដែរពីតម្រូវការ ក្នុងការទាក់ទាញពលកររកម្ពុជាដែលចេញទៅនោះ អោយត្រលប់មកថៃវិញ ដើម្បីបញ្ចៀសការខូចខាតដល់សេដ្ឋកិច្ច[xxvi]។

នៅថ្ងៃទី១៧ មិថុនា ឧត្តមសេនីយ៍ចាន់អូចា បានប្រកាសដល់និយោជកថៃក្នុងការចុះឈ្មោះពលករបរទេស និងបានគម្រាមដាក់ទណ្ឌកម្មមន្ត្រីណា ដែលពាក់ព័ន្ធអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ខុសច្បាប់[xxvii]។ NCPO បានបង្កើតលេខប្រចាំការសម្រាប់ទាក់ទងលើបញ្ហាពលកម្ម បន្ទាប់ពីពលករកម្ពុជាវិលទៅកម្ពុជាវិញយ៉ាងច្រើនដល់ទៅ ២០០.០០០ និង "បានជម្រុញអោយពលករទាំងនោះ ដែលត្រូវបានបញ្ជូនត្រលប់តាំងពីថ្ងៃទី១ មិថុនា សុំអោយវិលមកថៃវិញជាមួយឯកសារស្របច្បាប់"[xxvi]។

ភាពធ្ងន់ធ្ងរនៃកង្វះពលកម្មត្រូវបានមើលឃើញយ៉ាងឆាប់រហ័ស ក្នុងប្រទេសថៃ ហើយនៅថ្ងៃទី១៩ មិថុនា ក្រសួងការងារបានជម្រុញអោយប្រតិបត្តិករអាជីវកម្ម ដែលកំពុងប្រឈមមុខនិងកង្វះពលកម្ម ដោយសារតែលំហូរចេញដ៏គំហុកនៃពលកររកម្ពុជា មករាយការណ៍ពីតម្រូវការកម្លាំងពលកម្មរបស់ខ្លួន ដើម្បីអាចអោយក្រសួងការងារជួយបំពេញចន្លោះខ្វះខាតនេះ[xxx]។

ថ្ងៃទី២០ មិថុនា យោធាថៃបានបញ្ជូនពលកររកម្ពុជាដែលគ្មានឯកសារ ១.៣០០នាក់ទៅផ្ទះវិញ នាំអោយចំនួនសរុបនៃពលកររកម្ពុជាដែលបញ្ជូនត្រលប់ ឬគេចចេញពីប្រទេសថៃកើនដល់ ២២៦.០០០ នាក់គិតចាប់ពី២សប្តាហ៍មុន[xxx]។

ទោះជាយ៉ាងណា ក្នុងអំឡុងពេលនេះ លំហូរពលកររកម្ពុជាហាក់ដូចជាចាប់ផ្តើមមានលំហូរបញ្ច្រាស

ឬក៏នៅគាំងស្មៀម។ យោងតាមវរៈសេនីយ៍ ភីជិត មីយុនស៊ុត មេបញ្ជាការនៃបញ្ជាការដ្ឋានកងកម្លាំងពិសេស ក្រោមការគ្រប់គ្រងរបស់យោធភូមិភាគទី១២ បានបង្ហើបថាមានពលករកម្ពុជាជាង១០០នាក់បានចូលទឹកដីថៃតាមស្រុកអារញ្ញប្រាថេត នៃខេត្តស្រះកែវ ពីក្រុងប៉ោយប៉ែត នៅថ្ងៃទី២០ មិថុនា[xxxi]។ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ ឯកឧត្តម កុយ គួង មានប្រសាសន៍នៅថ្ងៃទី២០ មិថុនាថា ក្រសួងការបរទេសកម្ពុជា បានចុះឈ្មោះពលករកម្ពុជា ៥០.០០០នាក់ ដើម្បីធ្វើការស្របច្បាប់នៅប្រទេសថៃ ក្នុងនោះមានប្រហែល ២០.០០០នាក់ បានវិលមកថៃវិញរួចហើយ[xxxii]។

## ៣.២. សាវតារនៃពលករដែលបានវិលត្រលប់មកកម្ពុជា

ក្រុមស្រាវជ្រាវរបស់ MMN បានធ្វើការសម្ភាសន៍ចន្លោះពីខែកក្កដា ដល់ខែសីហា ២០១៤។ ជាសរុប MMN បានសម្ភាសន៍ពលករកម្ពុជា ៦៧នាក់ នៅក្នុងប្រទេសកម្ពុជា ដែលទើបតែបានត្រលប់ទៅពីប្រទេសថៃ។ ភេទរបស់ពលករបានញែកចេញជា ៥២.២%ជាប្រុស និង៤៧.៨%ជាស្រី។ ភាគរយនៃពលករដែលច្រើនជាងគេ(៤៩.៣%) គឺចន្លោះពីអាយុ១៩ ដល់៣០ឆ្នាំ។ ភាគច្រើននៃអាយុប្រភេទទី២ គឺចន្លោះពីអាយុ៣១ដល់៤០ឆ្នាំ (២៩.៩%)។ ភាគច្រើននៃអ្នកផ្តល់ព័ត៌មាន (៨០.៦%) គ្មានឯកសារអ្វីទាំងអស់នៅពេលដែលពួកគាត់ធ្វើការនៅក្នុងប្រទេសថៃ ក្នុងពេលដែល ៧.៥% ធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់តាមរយៈទីភ្នាក់ងារជ្រើសរើសពលករ ប៉ុន្តែការអនុញ្ញាតការងារបានផុតកំណត់។

អ្នកផ្តល់ព័ត៌មានធ្លាប់បានធ្វើការក្នុងខេត្តជាច្រើនក្នុងទឹកដីថៃ ប៉ុន្តែភាគធំបំផុតនៃពលករទាំងនោះគឺនៅក្នុងខេត្តឈុនបូរី (៣៤.៣%) និងបាងកក (២២.៤%)។ ផ្នែកដែលពួកគាត់ធ្វើការធំបំផុតគឺ សំណង់ (៥២.២%) និងរោងចក្រ (២២.៤%)។ គួរអោយចាប់អារម្មណ៍ផងដែរ គឺផ្នែកដ៏ធំនៃអ្នកដែលបានផ្តល់ព័ត៌មានបាននៅក្នុងប្រទេសថៃតែពីរបីខែប៉ុណ្ណោះ មុនពេលវិលត្រលប់ទៅកម្ពុជាវិញ៖ ៣២.៨%នៅប្រទេសថៃតិចជាង៣ខែ ២០.៩%នៅចន្លោះពី៣ទៅ៦ខែ ១៤.៩%នៅចន្លោះពី១ទៅ២ឆ្នាំ និង១១.៩%នៅចន្លោះពី៦ខែទៅ១ឆ្នាំ។ ទោះបីជាទាំងនេះហួសពីទំហំនៃការស្រាវជ្រាវ អាចទៅរួចដែលថាពលកររយៈពេលវែងក្នុងប្រទេសថៃ អាចនិងនៅរង់ចាំមើលសិនថាតើស្ថានភាពប្រែប្រួលយ៉ាងណា មុនពេលសម្រេចចិត្តក្នុងការវិលត្រលប់។

ក្នុងចំណោមអ្នកផ្តល់ព័ត៌មាន១៣នាក់ ត្រូវបានសួរសំណួរបន្ថែមអំពីស្ថានភាពគ្រួសារ និងកម្មសិទ្ធិដីធ្លីដែលបានបន្ថែមទៅលើកម្រងសំណួរ បន្ទាប់ពីការស្រាវជ្រាវបានចាប់ផ្តើម។ ក្នុងចំណោម១៣នាក់នេះ ១០នាក់បានរៀបការនិង៣នាក់នៅលីវ។ ៨នាក់មានកូន។ មានតែម្នាក់គត់ដែលមានដីខ្លួនឯង ហើយ ៩នាក់ទៀតគ្រួសាររបស់ពួកគាត់មានដីធ្លីជាកម្មសិទ្ធិ។

រូបថតផ្តល់ដោយ CWCC



*កាបូបដាក់ឥវ៉ាន់របស់ពលករមកដល់ប៉ោយប៉ែត ប្រទេសកម្ពុជា*

**៣.៣. មូលហេតុអ្វី និងពួកគាត់ចាកចេញពីប្រទេសថៃដោយរបៀបណា?**

ពលករបានត្រលប់ទៅប្រទេសកម្ពុជាតាមមធ្យោបាយផ្សេងៗគ្នា និងមានមូលហេតុជាច្រើន។ ពលករភាគច្រើនដែលវិលទៅកម្ពុជាវិញ មិនត្រូវបានបង្ខំអោយចេញពីប្រទេសថៃដោយសារតែការចាប់ខ្លួន និងបញ្ជូនត្រលប់នោះទេ គឺមានតែ ១០.៩%នៃអ្នកផ្តល់ព័ត៌មានប៉ុណ្ណោះដែលមានបទពិសោធន៍បែបនោះ។ ៥៩.៨%នៃអ្នកដែលបានសម្ភាសន៍បានវិលទៅវិញដោយសារតែពួកគាត់បានឮសូរថា អាជ្ញាធរកំពុងធ្វើការបង្ក្រាបទៅលើពលករមិនមានឯកសារ ដូច្នោះពួកគាត់មានការភ័យខ្លាចនិងបានសម្រេចចិត្តក្នុងការចាកចេញ។ មូលហេតុធំទីពីរនៃការចាកចេញពីប្រទេសថៃគឺ គ្រួសារពលករនៅកម្ពុជាមានការបារម្ភ និងបានសុំអោយពួកគាត់ត្រលប់ទៅវិញសិន(១៧.៩%)។ មូលហេតុផ្សេងៗទៀតនៃការវិលត្រលប់ទៅកម្ពុជាវិញគឺដោយសារនិយោជករបស់ពួកគាត់ភិតភ័យនិងសុំអោយពួកគាត់ចាកចេញ(៩%) ទៅវិញដើម្បីធ្វើឬបន្តលិខិតឆ្លងដែន(៤.៥%) គ្រួសាររបស់ពួកគេសុំអោយត្រលប់ទៅវិញសិនដោយមូលហេតុផ្សេងៗ(៤.៥%) ពលករផ្ទាល់ឬគ្រួសារពួកគាត់មានជម្ងឺ(៣%) ឬដោយសារតែពួកគាត់អត់មានការងារធ្វើនៅប្រទេសថៃ (៣%)។

ក្នុងចំណោមអ្នកផ្តល់ព័ត៌មាន៧នាក់ដែលបានរាយការណ៍ថាត្រូវបានបញ្ជូនត្រលប់ ៥នាក់ត្រូវបានចាប់ខ្លួនដោយប៉ូលីសនៅកន្លែងធ្វើការរោងចក្រនិងសំណង់។ ២នាក់ទៀតបានប្រាប់ថាពួកគាត់បានប្រគល់ខ្លួនអោយប៉ូលីស ដោយសារពួកគាត់មិនអាចមានលទ្ធភាពចេញពីប្រទេសថៃដោយខ្លួនឯង។ អ្នកផ្តល់ព័ត៌មានចុងក្រោយគេ បាននិយាយថាគាត់ត្រូវបានចាប់ខ្លួននៅតាមផ្លូវត្រលប់ទៅកម្ពុជាវិញ។ ៥នាក់ក្នុងចំណោម៧នាក់នោះ ពួកគាត់ត្រូវបង់ថ្លៃក្នុងដំណើរការបញ្ជូនត្រលប់។

**៣.៤. តើការវិលត្រលប់ភ្លាមៗនេះ ជះឥទ្ធិពលដល់ពលករនិងគ្រួសារយ៉ាងណាខ្លះ?**

*"ខ្ញុំមានការបារម្ភណាស់ដោយសារកូនរបស់ខ្ញុំគ្មានប្រាក់ចំណូល។ កូនខ្ញុំនឹងត្រូវចំណាយលុយដើម្បីត្រលប់ទៅប្រទេសថៃវិញ។" (ម្តាយម្នាក់ក្នុងវ័យ៥០ឆ្នាំប្លាយ ដែលកូនគាត់មានអាយុជាង២០ឆ្នាំទើបនិងត្រលប់មកដល់កម្ពុជា។ កូនរបស់គាត់ធ្លាប់ធ្វើការផ្នែកកសិកម្មនៅថៃ ប៉ុន្តែគាត់មិនដឹងថាកូនគាត់ធ្វើការនៅកន្លែងណាពិតប្រាកដនោះទេ។ បានសម្ភាសន៍នៅប៉ោយប៉ែត ខែកក្កដា ២០១៤)*

ការវិលត្រលប់ភ្លាមៗ បណ្តាលអោយមានបញ្ហាថវិកាដល់ពលករជាច្រើន ពីព្រោះពលករជាច្រើនត្រូវខ្ចីលុយគេដើម្បីផ្គត់ផ្គង់ដល់ការចាកចេញរបស់ពួកគាត់ ធ្វើអោយកើតមាននូវបំណុលថវិកា។ ការចាកចេញពីប្រទេសថៃដ៏លឿននេះ បណ្តាលអោយអ្នកផ្តល់ព័ត៌មាន ៥៣.៧% ជាប់បំណុល និងក្នុងចំណោមនោះ ៤៤.៤% បានរាយការណ៍ថាពួកគាត់បានសងបំណុលដោយខ្លួនឯង ឬសមាជិកគ្រួសារពួកគាត់បានអោយខ្ចីលុយសិនដើម្បីទៅសងគេ។ ភាគច្រើននៃពលករដែលនៅជាប់បំណុល បង្ហាញពីក្តីបារម្ភពីកំណើនបំណុលដោយសារការប្រាក់ ឬបារម្ភពីការបាត់បង់ផ្ទះ ដែលពួកគាត់បានយកទៅដាក់ធានាក្នុងការទទួលបាននូវឥណទាន។

មានអ្នកផ្តល់ព័ត៌មានតែ ២២.៧%ប៉ុណ្ណោះ ដែលបានលើកឡើងថានិយោជកថៃរបស់ពួកគាត់នៅជំពាក់ប្រាក់ឈ្នួលពួកគាត់។ ទោះជាយ៉ាងណា ក្នុងចំណោមអ្នកដែលនិយោជកនៅជំពាក់ប្រាក់ឈ្នួលនោះ មានការបែងចែករវាងអ្នកដែលចង់ឬមិនចង់ទារប្រាក់ជំពាក់នោះ៖ ៤៦.៦%ចង់ទារប្រាក់ជំពាក់មកវិញ ប៉ុន្តែ៥៣.៣%ទៀតមិនចង់ទារមកវិញទេ។

## ៣.៥. តើពលករវិលត្រលប់ត្រូវដោះស្រាយដោយរបៀបណា?

មានការឆ្លើយតបជាច្រើន ចំពោះសំណួរអំពីរបៀបដែលពួកគាត់មានផែនការដោះស្រាយចំពោះការវិលត្រលប់ភ្លាមៗរបស់ពួកគាត់។ ភាគច្រើននៃអ្នកឆ្លើយ (៤៤.៨%) មានគម្រោងត្រលប់ទៅស្រុកកំនើតវិញ និងរង់ចាំរហូតដល់មានពេលល្អក្នុងការវិលទៅថៃវិញ។ ១៩.៤% ទៀតបាននិយាយថាពួកគាត់នឹងត្រលប់ទៅស្រុកកំណើតហើយរកការងារធ្វើនៅទីនោះ។ ភាគរយសំខាន់មួយទៀត ១៦.៤%បាននិយាយថា ពួកគាត់មិនដឹងថាត្រូវធ្វើអ្វីនោះទេ នៅពេលនេះ។

រូបថតផ្តល់ដោយ CWCC




*អង្គការមិនមែនរដ្ឋាភិបាលផ្តល់ជំនួយបន្ទាន់ដល់ពលករ*

ក្នុងលក្ខណៈនៃតម្រូវការថវិកាបន្ទាន់ អ្នកផ្តល់ព័ត៌មាន ៥៦.៧% បានបង្ហាញពីតម្រូវការចង់បានជំនួយរយៈពេលខ្លី។ ចម្លើយដែលបានមកពីគ្រួសារនៃពលករដែលទើបតែត្រលប់មកវិញ បានបែងចែកថាតើពួកគាត់បានទទួលជំនួយរយៈពេលខ្លីដែរឬទេ។ ចម្លើយនេះពិតជាគួរអោយចាប់អារម្មណ៍ណាស់ ដោយសារតែ៩២.១% នៃសមាជិកគ្រួសារដែលផ្តល់ព័ត៌មាន បាននិយាយថាសមាជិកគ្រួសារពលករបានផ្ញើរប្រាក់ទៅអោយពួកគាត់។ ក៏គួរកត់សម្គាល់ផងដែរថា សមាជិកគ្រួសារពួកគាត់ក៏បញ្ជាក់ពីការយល់ឃើញចំពោះផលប៉ះពាល់ដល់ពួកគាត់យ៉ាងណានោះ ដោយសារតែពេលនេះគាត់លែងបានទទួលប្រាក់បញ្ញើទៀត។ ខ្លះទៀតតបថាមិនមានបញ្ហាទេ ព្រោះពួកគាត់បានសន្សំប្រាក់ទុក តែអ្នកផ្សេងទៀតបាននិយាយថាពួកគាត់បារម្ភណាស់ នឹងមិនមានប្រាក់គ្រប់គ្រាន់ទ្រទ្រង់ការចំណាយសម្រាប់ចិញ្ចឹមជីវិតនិងការរៀនសូត្រ ខ្លួនឯងនិងអ្នកក្នុងបន្ទុក។ អ្នកផ្តល់ព័ត៌មាន ៦៨.៥% បាននិយាយថាគ្រួសារជាប់បំណុពីការបញ្ជូនសមាជិកគ្រួសារទៅធ្វើការនៅក្រៅប្រទេស ហើយខ្លះក្នុងចំណោមពួកគាត់និយាយថាពួកគាត់ភិតភ័យខ្លាចក្រែងទ្រព្យសម្បត្តិរបស់ពួកគាត់ ត្រូវបានរឹបអូស អាស្រ័យដោយបំណុលមិនបានបង់។

## ៣.៦. តើរដ្ឋាភិបាលកម្ពុជាឆ្លើយតបយ៉ាងណា ចំពោះការវិលត្រលប់ភ្លាមៗនៃប្រជាជនកម្ពុជា?

រដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ពលករវិលមកវិញរាប់ពាន់នាក់ មានតម្រូវការជាក់លាក់ដែលត្រូវតែដោះស្រាយ។ យោងតាមការសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា បានកំណត់ពីតម្រូវការបំផុតរបស់ពលករ គឺមធ្យោបាយធ្វើដំណើរពីច្រកព្រំដែនទៅស្រុកកំណើត ឱកាសការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លិខិតឆ្លងដែន និងមធ្យោបាយវិលត្រលប់ដោយស្របច្បាប់ទៅថៃវិញកាន់តែឆាប់កាន់តែល្អ។ អទិភាពនៃរដ្ឋាភិបាលកម្ពុជា បានឆ្លុះបញ្ចាំងថារដ្ឋាភិបាលបានទទួលស្គាល់ពីលទ្ធភាព មិនអាចទៅរួចក្នុងការផ្តល់ការងារដល់ពលករវិលមកវិញទាំងអស់នេះ ដូច្នេះពួកគាត់និងត្រូវ

ការត្រលប់ទៅថៃវិញ ដើម្បីឧបត្ថម្ភថវិកាដល់គ្រួសាររបស់ពួកគេ។




រូបថតផ្ដល់ដោយ CWCC

*រដ្ឋាភិបាលកម្ពុជាដាក់រថយន្តទាហ៊ានដើម្បីនាំយកពលករទៅខេត្តកំណើត (ប៉ោយប៉ែត កម្ពុជា)*

រដ្ឋាភិបាលថ្នាក់ក្រោមជាតិបាននិយាយថា ពួកគាត់បានឆ្លើយតប ដោយការផ្ដល់អាហារដល់ពលករដែលទើបនិងមកវិញថ្មីៗ ការដឹកជញ្ជូនដោយមិនគិតសោហ៊ុយពីព្រំដែនទៅដល់ភូមិកំណើត និងផ្គត់ផ្គង់ថ្នាំពេទ្យ។ ពួកគាត់ក៏បានប្រឹងប្រែងប្រមែប្រមូលការឧបត្ថម្ភពីអាជីវករក្នុងមូលដ្ឋាន ដើម្បីជួយពលករ។ បន្ថែមពីលើនេះ ពួកគាត់បានខិតខំយ៉ាងខ្លាំង ក្នុងការផ្ដល់ព័ត៌មានដល់ពលករវិលមកវិញនូវប្រព័ន្ធទេសន្តរប្រវេសន៍ស្របច្បាប់ ឯកសារ និងពីរបៀបចាត់ចែងប្រាក់បញ្ញើមកផ្ទះ។ ការពិភាក្សាយោបល់ ជាមួយពលករដែលគ្មានដីធ្លីបានរៀបចំនៅក្នុងក្រុងមួយ ដើម្បីជួយពលករក្នុងការទិញដីសម្រាប់សង់លំនៅដ្ឋានតាមរយៈឥណទានធនាគារ។ នៅថ្ងៃទី១៦ មិថុនា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្ដម ស ខេង បានបង្ហាញពីក្ដីសង្ឃឹមថាពលករដែលវិលមកវិញនឹងរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជា ដោយការចូលរួម មជ្ឈមណ្ឌលបណ្ដុះបណ្ដាលរបស់រដ្ឋាភិបាល និងស្វែងរកការងារនៅក្នុងប្រទេសកម្ពុជា ដែលកំពុងមានការខ្វះខាតទីផ្សារពលកម្ម[xxxiii]។ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមន្ទីរការងារនិង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ក៏បានថ្លែងថាបានផ្ដល់ព័ត៌មានជាមូលដ្ឋាន ពីការងារក្នុងប្រទេសដែលនៅទំនេរ និងវគ្គបណ្ដុះបណ្ដាលជំនាញដោយមិនគិតប្រាក់សម្រាប់ពលករវិលមកវិញនៅខេត្តនីមួយៗ។ ទោះជា យ៉ាងណាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញ មានការខ្វះខាតធនធាន និងថវិកា ក្នុងការផ្ដល់សម្ភារៈចាំបាច់ឬបុគ្គលិកបង្រៀន ដើម្បីបណ្ដុះបណ្ដាលពលករ អោយបានសមរម្យ និងរបាំងថវិកានេះបាន ធ្វើអោយជនជាតិកម្ពុជាជាច្រើន មិនបានទទួលវគ្គបណ្ដុះបណ្ដាលនេះ។

រដ្ឋាភិបាលកម្ពុជាក៏បានប្រឹងប្រែង ក្នុងការជម្រុញទេសន្តរប្រវេសន៍ស្របច្បាប់ទៅប្រទេសថៃ។ ផ្នែកមួយនៃវិធានការជាច្រើននោះ អាជ្ញាធរមូលដ្ឋានបានខិតខំបង្កើនល្បឿន ដែលអាចផ្ដល់ឯកសារអត្រានុ

កូលដ្ឋានដូចជាសំបុត្រកំណើត និងសៀវភៅគ្រួសារ ដើម្បីជួយដល់ពលករវិលត្រលប់ទទួលបាននូវឯកសាររបស់ពួកគាត់ ក្នុងការចាកចេញពីប្រទេសសារជាថ្មី។ បន្តមកទៀត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានចុះហត្ថលេខាលើអនុក្រឹតដែលបញ្ចុះតម្លៃធម្មតានៃលិខិតឆ្លងដែនពី១២៤ដុល្លា ទៅត្រឹមតែ៤ដុល្លា សម្រាប់និស្សិតនិងពលករទេសន្តរប្រវេសន៍។

នៅថ្ងៃទី២៤ មិថុនា ក្រសួងការងារបានជួបជាមួយទីភ្នាក់ងារជ្រើសរើសពលករជាង៤០ ដើម្បីពិភាក្សាកែលំអនិងជម្រុញដំណើរការទេសន្តរប្រវេសន៍ស្របច្បាប់។ យោងទៅតាមរដ្ឋមន្ត្រីក្រសួងការងារឯកឧត្តម អ៊ិត សំហេង "ទីភ្នាក់ងារជ្រើសរើសពលករនឹងត្រូវបានផ្តល់អំណាច ក្នុងការជួយសម្រួលដល់ពលករដែលត្រូវបង់ថ្លៃសរុបតែ៤៩ដុល្លា សម្រាប់លិខិតឆ្លងដែន ការអនុញ្ញាតការងារនិងទិដ្ឋាការការងារថៃ រួមជាមួយការដឹកជញ្ជូននិងអាហារ[xxxv]។ ទាំងនេះ នឹងអនុញ្ញាតអោយទីភ្នាក់ងារជ្រើសរើសពលករក្នុងការគាំទ្រដល់ពលករ ជាជាងរង់ចាំអោយនិយោជកថៃចុះឈ្មោះសម្រាប់ពលករ ដូចដែលតម្រូវនៅក្នុងអនុសារណៈរវាងប្រទេសកម្ពុជានិងប្រទេសថៃ។

នៅថ្ងៃទី១១ កក្កដា ក្រសួងការបរទេសបានប្រកាសអោយពលករកម្ពុជាដែលគ្មានឯកសារទាំងអស់នៅក្នុងប្រទេសថៃធ្វើការចុះឈ្មោះ ដើម្បីទទួលបាននូវការអនុញ្ញាតការងារស្របច្បាប់នៅកន្លែងណាមួយនៃមជ្ឍមណ្ឌលច្រកចេញចូលតែមួយថៃ សម្រាប់ការចុះឈ្មោះពលករទេសន្តរប្រវេសន៍ និងបានថ្លែងថាការិយាល័យសាខាលិខិតឆ្លងដែនថ្មី និងបើកនៅទីតាំងបួនជាប់តាមព្រំដែន[xxxvi]។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសរួមគ្នាលេខ២៥៧៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ សម្រួលដល់ការផ្តល់ជូននូវលិខិតឆ្លងដែនតាមមជ្ឍមណ្ឌលច្រកចេញចូលតែមួយនៅកម្ពុជា។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានរៀបចំនីតិវិធីផងដែរក្នុងការជម្រុញអោយពលករទេសន្តរប្រវេសន៍ធ្វើការស្របច្បាប់នៅក្នុងប្រទេសថៃ តាមមជ្ឍមណ្ឌលទាំងនេះនៅក្នុងខេត្តបន្ទាយមានជ័យ(ប៉ោយប៉ែត) ប៉ៃលិន(ព្រំ) ឧត្តរមានជ័យ(អូរស្មាច់)និងកោះកុង(ចាំយាម)។

ទោះជាយ៉ាងណា រដ្ឋាភិបាលកម្ពុជាបានប្រឈមទៅនិងកត្តាលំបាកជាច្រើនក្នុងការពន្លឿនដំណើរការផ្តល់លិខិតឆ្លងដែន និងធានាអោយបានថាពលករចូលទៅកាន់ប្រព័ន្ធទេសន្តរប្រវេសន៍ស្របច្បាប់។ ពលករបានឃើញថានីតិវិធីគឺស្មុគស្មាញខ្លាំង ហើយជាទូទៅគ្មានព័ត៌មានគ្រប់គ្រាន់ពីទេសន្តរប្រវេសន៍ស្របច្បាប់និងប្រកបដោយសុវត្ថិភាព។ ដើម្បីទទួលបាននូវតម្លៃលិខិតឆ្លងដែនពិសេសវិញ ជាដំបូងប្រជាជនកម្ពុជាត្រូវតែបង្ហាញភស្តុតាងពីការបម្រើការងារពីនិយោជកថៃ ឬទីភ្នាក់ងារជ្រើសរើសពលករ ហើយក៏ត្រូវស្នើការបញ្ជាក់ពីក្រសួងការងារ ដែលបានធ្វើអោយដំណើរការកាន់តែស្មុគស្មាញនិងមាន

អ្នកជាច្រើនប្រឈមទៅនិងផលលំបាកផ្នែកពេលវេលា[xxxvii]។ លើសពីនេះទៀត ពលករវិលត្រលប់កម្ពុជាខ្លះ បានចាកចេញពីសហគមន៍របស់ពួកគេរួចជាស្រេចទៅប្រទេសថៃសារជាថ្មី។

ការវិលមកវិញភ្លាមៗ នៃពលករកម្ពុជាច្រើននោះ បានបណ្តាលអោយអាជ្ញាធរមូលដ្ឋានធ្វើការវាយតម្លៃឡើងវិញ ចំពោះគោលនយោបាយនិងទិសដៅរបស់ពួកគេ ពាក់ព័ន្ធនិងទេសន្តរប្រវេសន៍។ គោលនយោបាយថ្មីរបស់រដ្ឋាភិបាល ត្រូវបានផ្តោតលើការលើកកម្ពស់ទេសន្តរប្រវេសន៍ស្របច្បាប់បន្ថែម បង្កើតនីតិវិធីកាន់តែមានភាពសក្តិសិទ្ធិសម្រាប់ទេសន្តរប្រវេសន៍ការងារ និងបង្កើតកម្មវិធីសមាហរណកម្មសម្រាប់ពលករដែលវិលមកវិញ។ នៅពេលដែលរដ្ឋាភិបាលកំពុងតែព្យាយាមសម្របសម្រួលដល់ទេសន្តរប្រវេសន៍ អាជ្ញាធរមូលដ្ឋានខ្លះក៏កំពុងតែព្យាយាមជម្រុញអោយពលករទេសន្តរប្រវេសន៍ធ្វើការងារនៅក្នុងតំបន់ ដើម្បីបំពេញចន្លោះតម្រូវការការងារពលកម្មនៅក្នុងប្រទេសកម្ពុជា។ ផ្អែកទៅតាមទីភ្នាក់ងារជាតិមុខរបរកម្ពុជា ឃើញថាមានការងារ ១៦១៤៦កន្លែងនៅទំនេរ ត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤[xxxviii]។

## ៣.៧. តើផ្នែកអាជីវកម្មនិងនិយោជកមានប្រតិកម្មអ្វីដែរ?

ប្រតិបត្តិករអាជីវកម្មថៃមានការញាប់ញ័រ ដោយសារលំហូរចេញដ៏លឿន នៃពលករទេសន្តរប្រវេសន៍កម្ពុជា និងភ័យអំពីកង្វះពលកម្ម ដែលអាចពន្យឺតដល់ការអភិវឌ្ឍន៍ និងខូតខាតដល់ប្រទេសថៃដែលបានទន់ខ្សោយសេដ្ឋកិច្ចរួចស្រាប់ទៅហើយនោះ។ តំណាងសហគ្រាសសំណង់ ដាំដុះ នងពាណិជ្ជកម្មស្រូវ បានថ្លែងគ្រប់គ្នាថា ពួកគេធ្លាប់មានបទពិសោធន៍កង្វះពលកម្មដែលបានជះឥទ្ធិពលខូចខាតដល់សហគ្រាសរៀងៗខ្លួនរបស់ពួកគេ។ ដូចដែលបានពោលខាងលើ ប្រធានសមាគមខុនដូប្រទេសថៃ ប្រាសើត តៃឌុលឡាយ៉ាសាទីត បង្ហាញពីការយល់ឃើញថា កង្វះពលកម្មនឹងបណ្តាលអោយមានការយឺតយ៉ាវផ្សេងៗ[xxxix] ហើយប្រធានកិត្តិយសសមាគមអ្នកនាំអង្កចេញប្រទេសថៃ ឆូគៀត អូផាវង់ស៊ី បានថ្លែងថា "ដោយសារតែ៧០%នៃពលករពាក់ព័ន្ធនិងការលើកដាក់ស្រូវនៅឃ្លាំងផ្ទុក និងបញ្ជូនទៅលើកប៉ាល់បានចេញពីប្រទេស...អាចធ្វើអោយយឺតក្នុងការបញ្ជូនចេញប្រហែលជាពសប្តាហ៍[x1]។

សហគ្រាសទាំងនេះ បានបើកចំហរការភ័យខ្លាចរបស់ពួកគេជាសាធារណៈយ៉ាងលឿន ទៅដល់រដ្ឋាភិបាល និងបានជម្រុញអោយ NCPO បង្កើតនូវគោលនយោបាយពលកម្មបរទេសដ៏ច្បាស់លាស់មួយ។ ជាការឆ្លើយតប រដ្ឋលេខាធិការអចិន្ត្រៃយ៍ក្រសួងការងារ ជីរ៉ាសាក់ ស៊ុខុនថាឆាត បានប្រកាសថាក្រសួងការងារនឹងខិតខំប្រឹងប្រែងដើម្បីជួយរហូតដល់១.៥០០ប្រតិបត្តិករអាជីវកម្ម នៅខេត្តភាគបូព៌ានៃប្រទេស ដោយដាក់ជំនួស"ពលករមកពីតំបន់ផ្សេងៗទៀត ដើម្បីបំពេញចន្លោះខ្វះខាត ដូច្នេះគឺក្រុមហ៊ុនអាចបន្តអាជីវកម្មទៅមុខ"[x1i]គាត់បានទទួលដឹងថាមានការខ្វះកម្លាំងពលកម្មវិស័យដាំដុះ នេសាទ សេវាកម្ម និងសហគ្រាស ដោយសារតែលំហូរចេញថ្មីៗនៃពលករកម្ពុជា។ គាត់បង្គាប់អោយនិយោជកជូនដំណឹងដល់ក្រសួង ពីឈ្មោះក្រុមហ៊ុន និងចំនួនពលករដែលត្រូវការ ធ្វើដូច្នោះក្រសួងអាចព្យាយាមក្នុងការដាក់ជំនួសនូវពលករសម្រាប់ពួកគេ។

## ៣.៨. ការឆ្លុះបញ្ចាំងដោយពលករកម្ពុជាដែលបានវិលត្រលប់ ក្តីសង្ឃឹមសម្រាប់ពេលខាងមុខ ការឆ្លុះបញ្ចាំងពីដំណើរការទេសន្តរប្រវេសន៍

ពលករដែលបានវិលត្រលប់ចំនួន ៨០.៦%ដែលបានសម្ភាសន៍ក្នុងប្រទេសកម្ពុជា បាននិយាយថាពួកគាត់ចង់ត្រលប់ទៅប្រទេសថៃវិញ ក្នុងពេលដែល១៧.៩% ថាមិនចង់ទៅវិញទេ។ ៥១.៨%បាននិយាយថាពួកគាត់បានរៀបចំផែនការរួចហើយ ក្នុងការធ្វើទេសន្តរប្រវេសន៍ទៅថៃវិញទៀត។

> *"ខ្ញុំពិតជាចង់ធ្វើទេសន្តរប្រវេសន៍តាមប្រព័ន្ធផ្លូវការ។ ទោះជាយ៉ាងណាខ្ញុំមើលឃើញថានីតិវិធីពិតជាស្មុគស្មាញណាស់ ហើយខ្ញុំត្រូវរង់ចាំយ៉ាងយូរៗរីឯតម្លៃក៏ខ្ពស់ដែរ" (ពលករកម្ពុជាជាបុរសក្នុងវ័យ២០ឆ្នាំប្លាយ ដែលធ្លាប់ធ្វើការផ្នែកសំណង់នៅបាងកក មុនពេលវិលទៅកម្ពុជាវិញ។ បានសម្ភាសន៍នៅខែសីហា ២០១៨)*

ពលករក៏បានជួយផងដែរដល់ការបំភ្លឺអំពីអទិភាពរបស់ពួកគាត់ នៅពេលធ្វើទេសន្តរប្រវេសន៍ ក្នុងការជ្រើសរើសរវាងតម្លៃ ពេលវេលានិងភាពសក្តិសិទ្ធិ សុវត្ថិភាព ភាពស្របច្បាប់នៃការចូល និងព័ត៌មានដែលមាន។ អទិភាពខ្ពស់បំផុតសម្រាប់ពលករគឺតម្លៃថវិកា និងថាតើគួរជាមធ្យោបាយស្របច្បាប់ឬមិនស្របច្បាប់។ ភាគរយនៃអ្នកផ្តល់ចម្លើយដែលបានដាក់ចំនុចទាំងអស់នេះជាអទិភាពខ្ពស់បំផុតរបស់ពួកគេ គឺ៣៨.៥%គិតថាសុវត្ថិភាពក៏សំខាន់ដែរសម្រាប់ពួកគាត់ ជាមួយនិងពលករ៤៦.២% ចាត់ថ្នាក់ថាសុវត្ថិភាពជាអទិភាពទីពីររបស់ពួកគាត់។ បញ្ហាដែលពលករចាត់ថ្នាក់ជាអទិភាពតិចជាងគេនោះគឺព័ត៌មានដែលមាន ដែល៦១.៥%នៃពលករចាត់ថ្នាក់ថាជាការបារម្ភក្រោយគេបំផុតរបស់ពួកគាត់។

## ៣.៩. អនុសាសន៍ពលករកម្ពុជាដែលវិលត្រលប់មកវិញ

ក្នុងពេលសម្ភាសន៍ ពលករកម្ពុជាដែលបានវិលត្រលប់ ត្រូវបានសាកសួរដើម្បីចែករំលែកអនុសាសន៍របស់ពួកគាត់សម្រាប់រដ្ឋាភិបាលរបស់ពួកគាត់។ អនុសាសន៍បានបង្ហាញដោយអ្នកផ្តល់ការសម្ភាសន៍រួមមាន ការបញ្ចុះតម្លៃលិខិតឆ្លងដែន និងឯកសារស្របច្បាប់ចាំបាច់ដើម្បីធ្វើការនៅក្នុងប្រទេសថៃ បង្កើតការងារនិងសហគ្រាស នៅក្នុងប្រទេសកម្ពុជា និងសម្របសម្រួលទេសន្តរប្រវេសន៍ទៅកាន់ប្រទេសថៃ។ អ្នកផ្តល់ការសម្ភាសន៍ត្រូវបានសាកសួរពីអនុសាសន៍របស់ពួកគាត់សម្រាប់រដ្ឋាភិបាលថៃ ការឆ្លើយតបភាគធំគឺបានផ្តោតទៅលើការប្រតិបត្តិការរបស់ប៉ូលីសនិងទាហ៊ានទៅលើពលករ។ ពួកគាត់បានស្នើសុំកុំអោយរដ្ឋាភិបាលថៃចាប់ខ្លួនពលករទេសន្តរប្រវេសន៍ ហើយប្រសិនបើការចាប់ខ្លួនមិនអាចគេចផុតទេនោះ សូមអោយមានការគោរពសិទ្ធិមនុស្ស ជាពិសេសពីការដែលដាក់អោយពួកគាត់ស្នាក់នៅ អាហារ និងការដឹកជញ្ជូន។

ពលករដែលវិលត្រលប់ ត្រូវបានសួរនាំផងដែរដើម្បីចែករំលែកពីអនុសាសន៍របស់ពួកគេចំពោះអង្គការមិនមែនរដ្ឋាភិបាល។ អ្នកផ្ដល់ការសម្ភាសន៍បានស្នើសុំផងដែរដល់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្សព្វផ្សាយពីបញ្ហាសិទ្ធិពលករ ក្នុងការជួយពលករដែលរងនូវការបំពាន និងក្នុងការផ្ដល់ជំនួយផ្លូវច្បាប់ដល់ពលករដែលត្រូវបានគេជួញដូរ។ ជាចុងក្រោយ ពលករត្រូវបានសាកសួរពីអនុសាសន៍សម្រាប់និយោជកថៃ។ ពួកគាត់បានស្នើសុំកុំអោយនិយោជកបោកប្រាស់ពលករ បង្កើនប្រាក់ឈ្នួល ប្រព្រឹត្តចំពោះពលករក្នុងភាពជាមនុស្សនិងគោរពសិទ្ធិ និងជួលពលករវិញកាន់តែឆាប់កាន់តែល្អ ដែលឥលូវពួកគាត់កំពុងតែវិលទៅកម្ពុជាវិញ។

រូបថតផ្ដល់ដោយ MMN



*លក្ខខណ្ឌការងារនិងកន្លែងរស់នៅរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា*
*ក្នុងខេត្តរ៉ាក់យ៉ង ប្រទេសថៃ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤*

## ៤. ពលករបានទៅហើយ និងបានត្រលប់មកវិញ៖ ការយល់ឃើញពីប្រទេសថៃ

### ៤.១. គោលនយោបាយឆ្លើយតបចំពោះលំហូរចេញនៃពលករកម្ពុជាពីប្រទេសថៃ

ដូចដែលបានពន្យល់រួចហើយនៅក្នុងផ្នែកទី៣ ចាប់ផ្តើមពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ NCPO បានចាប់ផ្តើមបង្កើតគោលនយោបាយថ្មីស្តីពីពលករទេសន្តរប្រវេសន៍ នៅក្នុងប្រទេសថៃ។ ក្នុងពេលនោះបានបញ្ចេញបទសេចក្តីបង្គាប់លេខ ៦៧/២៥៥៧ ទាក់ទងនិង "វិធានការបណ្តោះអាសន្នក្នុងការដោះស្រាយចំពោះពលករទេសន្តរប្រវេសន៍"។ ក្នុងនោះ បានប្រកាសថាពួកគេគ្មានគោលនយោបាយ ដើម្បីបង្ក្រាបទៅលើពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃនោះទេ។ សេចក្តីបង្គាប់បន្តថ្លែងថា NCPO កំពុងពិចារណាធ្វើការអនុម័តលើការផ្លាស់ប្តូរបទបញ្ញា និងផ្លូវច្បាប់ ក្នុងការប្រព្រឹត្តចំពោះពលករទេសន្តរប្រវេសន៍ ប៉ុន្តែមិនមានភាពជាក់លាក់ទៅលើបំណងរបស់ NCPO នោះទេ។ ថ្ងៃទី១៧ មិថុនា NCPO បានបញ្ចេញសេចក្តីបង្គាប់លេខ ៦៨/២៥៥៧ ទាក់ទងនិង "វិធានការចន្លោះពេលបន្ទាន់ ក្នុងការទប់ស្កាត់និងបង្ក្រាបអំពីជួញដូរមនុស្ស និងដោះស្រាយបញ្ហាពាក់ព័ន្ធដល់ពលករទេសន្តរប្រវេសន៍ ជំហ៊ានទី១"។ សេចក្តីបង្គាប់ សំដៅដោយមិនច្បាស់លាស់ទៅសេចក្តីត្រូវការ ក្នុងការតាមដានមើលពីនីតិវិធីផ្លូវច្បាប់ ដើម្បីធានាថាពលករទេសន្តរប្រវេសន៍មានការការពារនៅកន្លែងធ្វើការ។

នៅថ្ងៃទី២១ មិថុនា NCPO បានប្រកាសពីផែនការក្នុងការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយដើម្បីចុះឈ្មោះពលករទេសន្តរប្រវេសន៍ ក្រោមវិធានការបន្ទាន់ ក្នុងការដោះស្រាយបញ្ហាយូរហើយនៃកម្លាំងពលកម្មអន្តរជនជាតិ។ OSSC នឹងពន្លឿននីតិវិធីឯកសារសម្រាប់ពលករមកពីប្រទេសជិតខាងដែលជាចំណែកនៃវិធានការសន្តិសុខ ដើម្បីធានាពីការទទួលបានរបស់ពួកគេចំពោះផលប្រយោជន៍ផ្នែកសិទ្ធិពលកម្ម។អាជ្ញាធរក៏បានលុបចោលនូវកំហិតផ្លូវច្បាប់ ក្នុងការផ្តល់លទ្ធភាពអោយពលករដែលបានស្នាក់នៅលើសកំណត់ទិដ្ឋាការ បានបន្តធ្វើការងាររបស់ពួកគេ។

នៅថ្ងៃទី២៥ មិថុនា NCPO បានចេញសេចក្តីបង្គាប់លេខ៧០/២៥៥៧ ទាក់ទងនិង "វិធានការក្នុងចន្លោះពេលក្នុងការដោះស្រាយបញ្ហាពលករទេសន្តរប្រវេសន៍និងអំពើជួញដូរមនុស្ស"។ សេចក្តីបង្គាប់បានប្រកាសថាមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ការវិលត្រលប់នៃពលករកម្ពុជា នឹងត្រូវបង្កើតនៅក្នុងខេត្តស្រះកែវ ចាន់ថាបូរី ត្រាត និងសុរិន្ទ នៅថ្ងៃបន្ទាប់។ ជនជាតិកម្ពុជាដែលមានបំណងចង់ចូលប្រទេសថៃមកធ្វើការអាចចុះឈ្មោះ ហើយមជ្ឈមណ្ឌលនឹងសម្របសម្រួលកិច្ចការរបស់ពលករទៅកន់និយោជកដែលបានចុះឈ្មោះរួចហើយ ពីចំណាប់អារម្មណ៍ចង់បានកម្លាំងពលកម្ម ហើយក៏ផ្តល់ជូនដល់ពលករផងដែរនូវការអនុញ្ញាតអោយចូលបណ្តោះអាសន្ន សម្រាប់គោលបំណងខាងលើ។ បន្ទាប់មកទៀតនិយោជក ត្រូវតែបន្តស្នើសុំការអនុញ្ញាតការងារបណ្តោះអាសន្នសម្រាប់និយោជិតរបស់

ខ្លួនពី OSSC ក្នុងមូលដ្ឋាន ដែលមាននៅ១កន្លែងនៅក្នុងនីមួយៗ។ជនជាតកម្ពុជាដែលមានបំណងក្នុងការចូលមក FCRCW ត្រូវតែចុះឈ្មោះត្រឹមថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤។ បន្ទាប់ពីកាលបរិច្ឆេទនេះ និងក្រៅពីអ្វីដែលបានផ្តល់ជូននៅពេលនេះ ច្បាប់អន្តោប្រវេសន៍នឹងត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ ដែលស្នើសុំការសង្កត់ធ្ងន់ទៅលើចាប់ពលករមិនមានឯកសារ។

ទោះជាយ៉ាងណា មិនត្រឹមតែអាជ្ញាធរផ្នែកអន្តោប្រវេសន៍និងពលកម្មការងារនោះទេ ដែលទាក់ទិននិងដំណើរការធ្វើអោយត្រឹមត្រូវតាមច្បាប់នៃពលករ។ រំពឹងទុកថាចំនួនដ៏ធំនៃពលកររកម្ពុជាក្នុងការវិលចូលប្រទេសថៃវិញ នៅថ្ងៃទី២៦ មិថុនា ក្រសួងសុខាភិបាលសាធារណៈ បានប្រញាប់ប្រញាល់បញ្ជូនក្រុមការងារទៅកាន់ខេត្តជាប់ព្រំដែន រួមមានស្រះកែវ ត្រាត សុរិន្ទ និងស៊ីសាកេត ដើម្បីផ្តល់ការពិនិត្យសុខភាព និងលក់ប័ណ្ណធានារ៉ាប់រ៉ងសុខភាព ទៅដល់ពលកររកម្ពុជាដែលវិលមកថៃវិញ ក្នុងអត្រាតម្លៃមួយបន្ថយជាងមុន[xlii]។

NCPO បានបន្តបដិសេធការចុះបង្រ្កាបពីដំបូងរបស់ខ្លួន នៅក្នុងសន្និសីទសារព័ត៌មាននៅក្នុងខេត្តស្រះកែវនៅថ្ងៃទី២៧ មិថុនា។ អភិបាលខេត្តស្រះកែវ ផ្រាការ៉ាថន ទៀនឆៃ នៅតែនិយាយថារដ្ឋាភិបាលថ្មីមិនបានបង្ក្រាបទៅលើពលកររទេសន្តរប្រវេសន៍នោះទេ...រដ្ឋាភិបាលអះអាងជាថ្មីថាវិធីដែលល្អបំផុតគឺបង្កើតមជ្ឈមណ្ឌលសម្រាប់ពលកររទេសន្តរប្រវេសន៍ ដើម្បីស្វែងរកការងារដែលមានសុវត្ថិភាពស្របតាមច្បាប់រដ្ឋ និងផ្តល់ជូននូវប្រាក់ឈ្នួលប្រសើរ[xliii]។

ទេសន្តរប្រវេសន៍ត្រលប់មកប្រទេសថៃវិញ បានចាប់ផ្តើមកើនឡើងនៅជិតចុងខែ ដែលពលករកម្ពុជា ១.០០០នាក់បានចូលមកប្រទេសថៃជាប្រចាំថ្ងៃតាមច្រកប៉ោយប៉ែត នៅថ្ងៃទី៣០ មិថុនា និងថ្ងៃទី១ កក្កដា[xliv]។ NCPO បានបន្តការប្រឹងប្រែងថ្មីរបស់ខ្លួនក្នុងការគ្រប់គ្រងកម្លាំងពលកម្មរបស់ពលករ និងធ្វើអោយប្រសើរឡើងនូវមុខមាត់ជាអន្តរជាតិរបស់ខ្លួន ពាក់ព័ន្ធនិងអំពើជួញដូរមនុស្ស ដោយបញ្ចេញនូវសេចក្តីបង្គាប់ថ្មីៗទាក់ទងនិងការបង្កើត OSSC ក្នុងខេត្តផ្សេងៗបន្ថែមទៀត។ នៅថ្ងៃទី៣ កក្កដា NCPO បានប្រកាសសេចក្តីបង្គាប់លេខ ៧៧/២៥៥៧ "ការបង្កើត OSSC បន្ថែមសម្រាប់ការចុះឈ្មោះពលកររទេសន្តរប្រវេសន៍និងវិធានការគ្រប់គ្រងអោយមានសណ្តាប់ធ្នាប់នៃពលកររទេសន្តរប្រវេសន៍ ធ្វើការនៅលើកប៉ាល់នេសាទ នៅតាមខេត្តជាប់សមុទ្រ"។ បន្ថែមពីលើនេះ ត្រឹមថ្ងៃទី២១ កក្កដា និយោជកនៃពលកររទេសន្តរប្រវេសន៍ធ្វើការលើកប៉ាល់នេសាទត្រូវបានបង្គាប់អោយធ្វើបញ្ជីរាយឈ្មោះលំអិត ជនជាតិ និងចំនួននៃពលកររទេសន្តរប្រវេសន៍របស់ពួកគេ និងជូនដំណឹងដល់មន្ទីរការងារខេត្ត ដែលកប៉ាល់របស់ពួកគេត្រូវបានចុះបញ្ជីនៅទីនោះ។ ត្រឹមថ្ងៃទី២៦ កក្កដា នាយកដ្ឋានការងារ បានប្រកាសថាប្រតិបត្តិការអូសអួននេសាទចំនួន ៣.៣១៥នាក់ (ក្នុងចំណោម ១០.០០០ ដែលកំពុងប្រតិបត្តិការ) បានបញ្ជូនបញ្ជីជាមួយឈ្មោះពលករ ៥៤.៧៨៩នាក់ ក្នុងនោះ ៤៥.៣៥៧នាក់មិនមានឯកសារ[xlvi]។

រូបថតផ្តល់ដោយ MMN



*ពលករនេសាទលើកដាក់ត្រីដែលចាប់បាននៅក្នុងខេត្តត្រាត ប្រទេសថៃ*
*ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤*

សកម្មភាពទាំងឡាយរបស់ NCPO ក្នុងការធ្វើអោយស្របច្បាប់នូវស្ថានភាពរបស់ពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេសថៃ ទទួលបានការគាំទ្រពីរដ្ឋាភិបាលកម្ពុជា មីយ៉ាន់ម៉ា និងឡាវ នៅថ្ងៃទី៧ កក្កដា នៅពេលដែលឯកអគ្គរាជទូតនិងរដ្ឋទូតនៃប្រទេសទាំងបី ចូលរួមជាមួយមន្ត្រីថៃ ក្នុងការចុះអធិការកិច្ច OSSC នៅក្នុងខេត្តសាមុតប្រាកាន។ រាជទូតនិងរដ្ឋទូតទាំងអស់ បានបង្ហាញពីការគាំទ្រដល់បទបញ្ជាកម្លាំងពលកម្មនៃប្រទេសថៃ ដោយបាននិយាយថា នឹងលប់ចោលនូវបញ្ហាជាច្រើន ព្រមទាំងការពារពលករពីការរំលោភបំពានសិទ្ធិមនុស្ស[xlvii]។

ថ្ងៃបន្ទាប់មកទៀត NCPO លើកឡើងទៀតថា ដើម្បីទទួលបាននូវការអនុញ្ញាតការងារសម្រាប់ពលករ នឹងតម្រូវអោយពលករត្រូវតែឆ្លងកាត់ការពិនិត្យសុខភាពសិន ដែលមានតម្លៃ១៥ដុល្លា និងទិញធានារ៉ាប់រងតម្លៃ ១.៦០០បាត។ ចំនុចនេះមិនមែនគោលការណ៍ថ្មីនោះទេ តែពេលនេះការអនុវត្តមានការតឹងតែងជាងមុនជាខ្លាំង។ ក្រសួងសុខាភិបាលថៃ បង្គាប់អោយពលករស្នើធ្វើការអនុញ្ញាតរយៈពេល១ឆ្នាំ ដើម្បីពិនិត្យលើអំហ្វេតាមីន និងជម្ងឺចំបងៗផ្សេងទៀតរួមមាន ជម្ងឺស្វាយ ជម្ងឺឃ្លង់ ជម្ងឺបណ្តុំសរសៃតាមរយៈថតកាំរស្មីអ៊ិចទ្រូង និងជម្ងឺរបេង[xlviii]។ អ្នកណាដែលរកឃើញថាក្រោមឥទ្ធិពលនៃអំហ្វេតាមីន ជម្ងឺស្វាយដំណាក់កាលទី៣ ជម្ងឺផ្លូវចិត្ត ញៀនស្រា របេងរ៉ាំរ៉ៃ ឃ្លង់រ៉ាំរ៉ៃ ឬសរសៃរ៉ាំរ៉ៃនឹងត្រូវបានបញ្ជូនត្រលប់។ អ្នកដែលរកឃើញថាមានជម្ងឺរបេង ស្វាយ ឃ្លង់ ឬសរសៃ ដំណាក់កាលដំបូងនឹងតម្រូវអោយបន្តការព្យាបាលមុនពេលផ្តល់នូវការអនុញ្ញាតការងារ។

រូបថតផ្តល់ដោយ MMN



*ពលករមកធ្វើការពិនិត្យសុខភាពនៅ OSSC ក្នុងខេត្តរ៉ាក់យ៉ង ប្រទេសថៃ*

NCPO បានបន្តការប្រឹងប្រែងក្នុងការតាមមើល ពីស្ថានភាពអន្តោប្រវេសន៍នៃពលករនៅក្នុងប្រទេសថៃ នៅថ្ងៃទី២០ កក្កដា ដោយតម្រូវអោយម្ចាស់ផ្ទះនៃពលករទេសន្តរប្រវេសន៍ក្នុងខេត្តសាមុតសាខន ក្នុងការផ្តល់នូវបញ្ជីឈ្មោះពលករដែលជួលផ្ទះ ដល់អាជ្ញាធរក្នុងពេល២៤ម៉ោង ឬអាចប្រឈមមុខចំពោះមុខច្បាប់ ដែលនេះជាផ្នែកមួយនៃការប្រឹងប្រែងធ្វើអោយផ្លូវការនូវជួលទ្រព្យសម្បត្តិ។ វរៈសេនីយ៍ចាការុធ ស៊ីនភូនភុន ជាអនុប្រធាន ISOC នៅខេត្តសាមុតសាខន និងជាប្រធានក្រុមអធិការកិច្ចផ្ទះស្នាក់នៅរបស់ពលករ បាននិយាយក្នុងការប្រជុំជាមួយម្ចាស់ផ្ទះថា ពួកគេត្រូវតែធ្វើកិច្ចសន្យាជួលសម្រាប់ការត្រួតពិនិត្យ។ ម្ចាស់ផ្ទះត្រូវបានប្រាប់ថា ពួកគេអាចក្លាយជាចុងចោទទីពីរក្នុងករណីផ្លូវច្បាប់ បើសិនជាមន្រ្តីចាប់ខ្លួនអ្នកជួលផ្ទះរបស់ពួកគេ សម្រាប់ការរំលោភច្បាប់[1]។

ក្នុងខែកក្កដាទាំងមូល NCPO បានបន្តចេញនូវសេចក្តីបង្គាប់ជាច្រើនក្នុងការបង្កើត OSSC តាមបណ្តាខេត្ត។ សេចក្តីបង្គាប់ចុះថ្ងៃទី២១ កក្កដា លេខ១១៧/២៥៥៧ បានប្រកាសថាក្នុងការបង្កើតទៅដល់៥៣ខេត្តបន្តទៀត ធ្វើអោយក្លាយទៅជាសេវាទូទាំងប្រទេស និងពន្យាការប្រតិបត្តិការគ្រប់មជ្ឈមណ្ឌលរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥[1i]។

សេចក្តីបង្គាប់ផ្សេងៗទៀតនៅថ្ងៃនោះគឺលេខ ១១៨/២៥៥៧ "វិធានការក្នុងចន្លោះពេលបន្ថែមដើម្បីទប់ស្កាត់និងបង្ក្រាបអំពើជួញដូរមនុស្ស និងដោះស្រាយបញ្ហាទាក់ទិននិងពលករទេសន្តរប្រវេសន៍"។ សេចក្តីបង្គាប់នេះ បានពន្យាអំឡុងពេលចុះឈ្មោះសម្រាប់ OSSC ក៏ដូចជា FCRCW ក្នុងខេត្តស្រះកែវ និងចាន់ថាប្វុរី រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ដូច្នេះពលករកម្ពុជាដែលមានបំណងត្រលប់ទៅធ្វើការនៅប្រទេសថៃ អាចបន្តស្នើសុំតាមរយៈ FCRCW ។ សេចក្តីបង្គាប់ ក៏បានពន្យារយៈពេលនៃសុពលភាពឯកសាររបស់ពលករ (ការអនុញ្ញាតការងារ និងប័ណ្ណសំគាល់ខ្លួនមិនមែនជាជនជាតិថៃ) ដែលបានផ្តល់ដោយ OSSC រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ និងបន្តការតម្រូវដល់ពលករ និងអ្នកក្នុងបន្ទុកត្រូវតែទិញការធានារ៉ាប់រ៉ងសុខភាព[1ii]។ ពីថ្ងៃទី៣០ មិថុនា ដល់ថ្ងៃទី១៥ កក្កដា ពលករជាង ១០០.០០០នាក់ បានទទួលសេវានិងបានទិញប័ណ្ណធានារ៉ាប់រ៉ង។

រូបថតផ្តល់ដោយ MMN




*ពលករទេសន្តរប្រវេសន៍ចុះឈ្មោះនៅ OSSC ក្នុងខេត្តរ៉ាក់យ៉ង ប្រទេសថៃ*

NCPO បានធ្វើសន្និសីទសារព័ត៌មាននៅថ្ងៃទី២៩ កក្កដា បានប្រកាសថារយៈពេលដែលផ្តល់ដល់ពលករមិនមានឯកសារពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ក្នុងការចុះឈ្មោះនិងទទួលការអនុញ្ញាតការងារបណ្តោះអាសន្ន ក្នុងប្រទេសថៃ នឹងមិនពន្យាពេលទៀតទេ។ ពួកគាត់បានណែនាំដល់ពលករធ្វើការរាយការណ៍ទៅ OSSC ត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ក្នុងគោលបំណងអោយពួកគាត់បានស្នាក់នៅនិងធ្វើការបណ្តោះអាសន្នក្នុងប្រទេសថៃ។ ពលករដែលបានចុះឈ្មោះរួចហើយ នឹងអនុញ្ញាតអោយប្រើប័ណ្ណសម្គាល់ខ្លួនមិនមែនជាជនជាតិថៃរបស់ពួកគាត់ អាចត្រលប់ទៅប្រទេសកំណើតវិញ ក្នុងការបំពេញដំណើរការពិសោធន៍សញ្ជាតិ និងស្នើសុំឯកសារចាំបាច់ផ្សេងៗ ទៀតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥[1iv]។

រូបថតផ្តល់ដោយ MMN



*ពលករទេសន្តរប្រវេសន៍រង់ចាំនៅ ក្នុងខេត្តរ៉ាក់យ៉ង ប្រទេសថៃ ថ្ងៃទី១១ សីហា ២០១៤*

ការិយាល័យរដ្ឋបាលពលករបរទេសនៃក្រសួងការងារ បានបញ្ចេញតួលេខនៅថ្ងៃទី៦ ខែវិច្ឆិកា ២០១៤ បង្ហាញពីចំនួនសរុបនៃពលករដែលបានចុះឈ្មោះមានរហូតដល់ ១.៤៩៣.៧៨១នាក់។ ក្នុងចំណោមនោះបែងចែកតាមជនជាតិមាន៖ ៦៨១.៥៧១ជាកម្ពុជា ៦០០.៨១៦ជាភូមា និង២១១.៣៩៤ជាលាវ។ ចំនួនសរុបនៃកុមារក្នុងបន្ទុកដែលបានចុះឈ្មោះមាន៩១.១៥៧នាក់ ដែលមានកុមារកម្ពុជា៤១.៦៩៥ កុមារភូមា៤០.៣៨៨ និងកុមារលាវ៩.០៧៤នាក់។ OSSC ក៏ជោគជ័យផងដែរក្នុងការចុះឈ្មោះដល់និយោជក ៣០៩.៦១០នាក់។ ខេត្តដែលមានចំនួនពលករចុះឈ្មោះច្រើនៗជាងគេ គឺបាងកក ៣០៨.៤៤៧នាក់ ខេត្តឈុនបូរី ១៩១.៩១៣នាក់ និងខេត្តសាមុតសាខន ៩៨.៣៥៧នាក់។ វិស័យការងារចំបងដែលពលករបានចុះឈ្មោះគឺ សំណង់(៤៧៩.២៣៦នាក់) កសិកម្ម(២១៥.៥៨៥នាក់) និងសេវា (១៣៨.៦០១នាក់)[lv]។

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤ លោកសុមេត ម៉ាហូសុត ជាអគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារថៃ បានប្រកាសថាចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤តទៅ វគ្គថ្មីនៃការពិសោធន៍សញ្ជាតិនៃពលករដែលចុះឈ្មោះចំនួន ១.២០០.០០០នាក់ពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ និងអ្នកក្នុងបន្ទុករបស់ពួកគេនិងចាប់ផ្តើម។ រដ្ឋាភិបាលកម្ពុជានឹងបញ្ជូនក្រុមមន្ត្រីការងារ៥ក្រុមមកប្រទេសថៃ ក្នុងការជួយដល់ដំណើរការពិសោធន៍សញ្ជាតិ ចាប់ផ្តើមនៅក្នុងខេត្តសាមុតប្រាកាន ខេត្តសាមុតសាខន ខេត្តនាក់ឆើងសៅ និងខេត្តឈុនបូរី ហើយពលករត្រូវចំណាយប្រមាន ១.៥០០បាតក្នុងម្នាក់។

NCPO បានបញ្ជាក់ពីជំហាររបស់ខ្លួនដែលថាពលករទាំងអស់ត្រូវតែចុះឈ្មោះត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤។នៅថ្ងៃទី២០ តុលា ISOC បាននិយាយថា"នឹងប្រើប្រាស់វិធានការចាំបាច់ក្នុងការបញ្ជូនត្រលប់នូវពលករណាដែលមិនបានចុះឈ្មោះ ទៅប្រទេសកំណើតវិញ"[lvii]។ បន្ថែមពីលើនេះ ក្រសួងការងារបានប្រកាសថានឹងសំលឹងមើលពី "គ្រឿងលើកទឹកចិត្តក្នុងការទាក់ទាញពលករថៃថែមទៀត ដើម្បីធ្វើការក្នុងវិស័យទេសចរ និងសហគ្រាសផ្សេងៗទៀត" ក្នុងគោលបំណងជំនួសអោយពលករទេសន្តរប្រវេសន៍មិនមានឯកសារ[lviii]។

## ៤.២. តើមានយន្តការបច្ចុប្បន្នអ្វីខ្លះ សម្រាប់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ?

### *ទេសន្តរប្រវេសន៍តាមទីភ្នាក់ងារជ្រើសរើសពលករ ជាដំណើរការមួយបង្កើតឡើងស្របតាមអនុសារណៈនៃការយោគយល់គ្នា*

ទេសន្តរប្រវេសន៍ផ្លូវការតាមទីភ្នាក់ងារជ្រើសរើសពលករ ដែលអនុលោមទៅតាមអនុសារណៈនៃការយោគយល់គ្នារវាងប្រទេសកម្ពុជានិងប្រទេសថៃ គឺជាដំណើរការស្មុគស្មាញ។ ពលករដែលបានធ្វើ

ទេសន្តរប្រវេសន៍ទៅប្រទេសថៃតាមប្រព័ន្ធផ្លូវការនេះ ត្រូវបានហៅថា "ពលករតាមអនុសារណៈ"។ ចំនួននៃពលករកម្ពុជាតាមអនុសារណៈ នៅក្នុងប្រទេសថៃ គិតត្រឹមថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៤មាន ៨៥.៧៣៣នាក់។ ពលករតាមអនុសារណៈ ត្រូវបានអនុញ្ញាតអោយធ្វើការក្នុងប្រទេសថៃសម្រាប់២ឆ្នាំ ហើយដែលពួកគាត់អាចសុំបន្តជាថ្មីបាន២ឆ្នាំម្តងទៀត។

ដំណើរការតាមអនុសារណៈនេះ តម្រូវអោយពលករស្នើសុំសេវាពីទីភ្នាក់ងារជ្រើសរើសពលករនៅក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវទាក់ទងផងដែរជាមួយនិយោជកថៃ ដែលស្វែងរកពលករ។ ទីភ្នាក់ងារជ្រើសរើសពលកររៀបចំបែបបទក្នុងនាមពលករសម្រាប់ប័ណ្ណពលករធ្វើការនៅបរទេសពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា។

នៅពេលដែលប័ណ្ណពលករធ្វើការនៅបរទេសត្រូវបានផ្តល់រួច ទីភ្នាក់ងារអាចដាក់ពាក្យស្នើសុំធ្វើលិខិតឆ្លងដែនសម្រាប់ពលករ និងរៀបចំការអនុម័តយល់ព្រមចំពោះឯកសារផ្សេងទៀត ពីអាជ្ញាធរថៃនិងកម្ពុជា។ នៅពេលដែលការអនុញ្ញាតទាំងអស់ត្រូវបានផ្តល់ជូនរួចហើយ ទីភ្នាក់ងារនឹងធ្វើការចាត់ចែងការដឹកជញ្ជូនពលករទៅទីតាំងការងារនៅប្រទេសថៃ។ ពេលទៅដល់ទីនោះ ពលករត្រូវតែរាយការណ៍ទៅអាជ្ញាធរអន្តោប្រវេសន៍ដើម្បីចុះឈ្មោះ និងទទួលបានការអនុញ្ញាតការងារជាក់ស្តែង។

### *មជ្ឈមណ្ឌលច្រកចេញចូលតែមួយសម្រាប់ការចុះឈ្មោះពលករទេសន្តរប្រវេសន៍នៅប្រទេសថៃ*

OSSC ត្រូវបានបង្កើតដើម្បីបម្រើសេវាដល់ក្រុមពលករនិងអ្នកក្នុងបន្ទុកពួកគាត់ ដែលមានអាយុក្រោម ១៥ឆ្នាំ បីប្រភេទៈ សម្រាប់អ្នកដែលបានចុះឈ្មោះក្នុងឆ្នាំ២០១៣អនុលោមតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីថៃ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៣ ដែលបានអនុម័តអោយពន្យាមួយឆ្នាំទៀតនៃពេលវេលាកំណត់សម្រាប់ការបញ្ចប់ដំណើរការធ្វើអោយស្របច្បាប់ ចំពោះពលករមិនមានឯកសារក្នុងប្រទេសថៃ និងពលករណាដែលការអនុញ្ញាតការងារអស់សុពលភាពត្រឹមថ្ងៃទី១១ ខែសីហា ២០១៤។ សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជា ដែលបានចុះឈ្មោះរួចហើយនៅ FCRCW និងពលករកម្ពុជាដែលមិនមានឯកសារត្រូវបានអនុញ្ញាតអោយធ្វើការជាមួយនិយោជកណាដែលបានធានាពួកគាត់នៅកន្លែងការងារដែលមានបញ្ជាក់លើការអនុញ្ញាតការងារ។ នៅពេលដែលបានចុះឈ្មោះរួច ពួកគាត់ត្រូវបានអនុញ្ញាតអោយស្នាក់នៅនិងធ្វើការនៅប្រទេសថៃត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

សម្រាប់ពលករដែលចុះឈ្មោះនៅ ជាដំបូងនិយោជករបស់ពួកគាត់ត្រូវតែរៀបចំឯកសារដែលតម្រូវ រួមមានទម្រង់ឯកសារមិនមែនជាជនជាតិថៃ ដែលបានផ្តល់ដោយរដ្ឋបាលខេត្ត(ក្រសួងមហាផ្ទៃ) ប័ណ្ណសំគាល់ខ្លួនថតចម្លង១ច្បាប់ និងឯកសារថតចម្លងនៃការចុះឈ្មោះគ្រួសាររបស់និយោជក១ច្បាប់។

និយោជកត្រូវតែជូនពលកររបស់ពួកគេទៅកាន់ OSSC និង ដាក់ឯកសារទាំងអស់នៅទីនោះ។ បន្ទាប់មក ពលករម្នាក់ៗត្រូវទទួលការពិនិត្យសុខភាពនៅ OSSC និងជួបជាមួយរដ្ឋបាលខេត្តដើម្បីកត់ត្រាទុកនូវជីវប្រវត្តិរបស់ពួកគាត់ រួមមានទាំងរូបថតនិងស្នាមមេដៃ។ បន្ទាប់មក រដ្ឋបាលខេត្តនឹងផ្តល់ឯកសារអនុញ្ញាតអោយស្នាក់នៅបណ្តោះអាសន្ន(ថរ៣៨/១)។

រូបថតផ្តល់ដោយ MMN



*ពលករទេសន្តរប្រវេសន៍ចុះឈ្មោះនៅ OSSC នាខេត្តត្រាត ប្រទេសថៃ ថ្ងៃទី១៤ សីហា ២០១៤*

តម្លៃនៃការដំណើរការចុះឈ្មោះសម្រាប់ពលករទេសន្តរប្រវេសន៍សរុប ៣.០៨០បាត ត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤។ តម្លៃរួមមាន ៩០០បាតសម្រាប់ការអនុញ្ញាតការងារ៣ខែ ៨០បាតសម្រាប់ ថរ៣៨/១ ៥០០បាតសម្រាប់ការពិនិត្យសុខភាព និង១.៦០០បាតសម្រាប់ធានារ៉ាប់រងសុខភាព។

ពលករទេសន្តរប្រវេសន៍នឹងត្រូវផ្តល់ជូននូវប័ណ្ណមិនមែនជនជាតិថៃ ដែលមានព័ត៌មានជាបឋម ព្រមទាំងព័ត៌មានពីការអនុញ្ញាតការងារ និងធានារ៉ាប់រងសុខភាព។

OSSC ត្រូវបានរៀបចំមកសម្រាប់ចុះឈ្មោះពលករដែលកំពុងតែនៅក្នុងប្រទេសថៃរួចស្រាប់ ប៉ុន្តែដោយសារតែដំណើរការចុះឈ្មោះ មានភាពលឿនជាងទេសន្តរប្រវេសន៍តាមប្រព័ន្ធអនុសារណៈនោះ ពលករដែលត្រូវបានសម្ភាសន៍ក្នុងរបាយការណ៍នេះ បាននិយាយថាពលករកម្ពុជាជាច្រើនជ្រើសរើសក្នុងការធ្វើប័ណ្ណព្រំដែនឆ្លងទៅប្រទេសថៃ រួមបន្តដំណើរទៅទំតាំងធ្វើការ និងចុះឈ្មោះនៅ OSSC ក្នុងមូលដ្ឋាននោះ។

> *"ដំណើរការសេវាច្រកចេញចូលតែមួយមិនស្មុគស្មាញទេ ហើយផ្តល់លទ្ធភាពអោយពលករកាន់តែច្រើនបានដាក់ពាក្យ។ ខ្ញុំគិតថាវាល្អជាងដំណើរការមុនៗ" (ស្ត្រីជាពលករកម្ពុជាក្នុងវ័យ៩០ឆ្នាំថ្លាយ បម្រើការនៅសហគ្រាសកែច្នៃអាហារសមុទ្រ។ បានសម្ភាសន៍ក្នុងខេត្តរ៉ាក់យ៉ង ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤)*

*"ដំណើរការនេះកាន់តែងាយស្រួល និងមានឧបសគ្គពេលវេលាតិចតួចជាមុនៗ ដោយសារតែឯកសារអីៗត្រូវធ្វើនៅតែមួយកន្លែង" (បុរសជាពលករកម្ពុជាក្នុងវ័យ ២០ឆ្នាំប្លាយ បម្រើការនៅរោងចក្រកែច្នៃអាហារសមុទ្រ។បានសម្ភាសន៍ក្នុង ខេត្តរ៉ាក់យ៉ង ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៨)*

ការធ្វើប័ណ្ណព្រំដែនអាចមានការពិបាកសម្រាប់ជនជាតិកម្ពុជាជាច្រើន ដោយសារតែប័ណ្ណនេះសម្រាប់តែប្រជាជនរស់នៅក្នុងមូលដ្ឋាននាខេត្តជាប់ព្រំដែន ដែលតែងតែធ្វើដំណើរទៅមកក្នុងប្រទេសថៃ។ ប័ណ្ណព្រំដែនមានតម្លៃតែ ៥ដុល្លាសម្រាប់ប្រជាជនក្នុងមូលដ្ឋាន និង១៥ដុល្លាសម្រាប់ជនជាតិកម្ពុជាផ្សេងទៀត[1ix]។ លើសពីនេះទៀត ត្រូវចំណាយ៧០បាតក្នុងពេលចូលទៅប្រទេសថៃម្តងៗ។ ដោយមិនគិតពីតម្លៃទាំងអស់នេះ ដំណើរការនេះហាក់ដូចជាជួយដល់ពលករកម្ពុជាជាច្រើនអោយបានត្រលប់ទៅធ្វើការនៅប្រទេសថៃវិញបានលឿន ហើយដែលជាអទិភាពខ្ពស់បំផុតសម្រាប់ពលករជាច្រើន។

## *មជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ទទួលពលករកម្ពុជា*

FCRCW ដែលបានបង្កើតដោយ NCPO មានទីតាំងនៅក្នុងខេត្តស្រះកែវ ចាន់ថាបូរី ត្រាតនិងសុរិន្ទ និងក្រោមការពិនិត្យមើលយ៉ាងជិតដល់ ពីការិយាល័យអន្តោប្រវេសន៍ នាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងនាយកដ្ឋានការងារនៃក្រសួងការងារ។

ទេសន្តរប្រវេសន៍តាមរយៈ FCRCW ចាប់ផ្តើមនៅពេលពលករកម្ពុជាដែលបានធ្វើប័ណ្ណព្រំដែន ឬលិខិតឆ្លងដែនដែលបានផ្តល់ដោយអាជ្ញាធរអន្តោប្រវេសន៍កម្ពុជា បានដាក់ឯកសាររបស់ពួកគាត់នៅកន្លែងត្រួតពិនិត្យអន្តោប្រវេសន៍ថៃ។ អន្តោប្រវេសន៍ថៃពិនិត្យឯកសារអន្តោប្រវេសន៍របស់ពលករ តាមប្រព័ន្ធអត្តសញ្ញាណបុគ្គល និងគ្រប់គ្រងអន្តោប្រវេសន៍ក្នុងបញ្ជីខ្មៅ និងអោយពួកគាត់ចាប់លេខរកកន្លែងអង្គុយចាំជាជួរ។ នៅពេលដែលពលកររង់ចាំឆ្លងកាត់ព្រំដែន អាជ្ញាធរថៃប្រាប់ដល់ពួកគាត់ពីគោលនយោបាយរបស់ NCPO ចំពោះការគ្រប់គ្រងពលករទេសន្តរប្រវេសន៍។ ជាយថាហេតុ គឺប៉ូលីសជូនពលករទាំងនេះឆ្លងកាត់ព្រំដែនទៅកាន់ FCRCW ។

រូបថតផ្ដល់ដោយ MMN



*ពលករកម្ពុជាដែលវិលត្រលប់កំពុងរង់ចាំទៅចុះឈ្មោះនៅ FCRCW ខេត្តស្រះកែវ ប្រទេសថៃ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៤*

នៅពេលដែលពលករមកដល់ FCRCW សម្រាប់ការចុះឈ្មោះ ជាដំបូងមន្ត្រីអន្តោប្រវេសន៍ផ្ទៀងផ្ទាត់ឯកសារអន្តោប្រវេសន៍របស់ពលករ។ បន្ទាប់មកទៀត ពួកគេបញ្ជូនឯកសារអនុម័តទៅអោយមន្ត្រីនៃនាយកដ្ឋានរដ្ឋបាលខេត្ត ក្នុងគោលបំណងផ្ដល់ជូននូវឯកសារស្នាក់នៅបណ្ដោះអាសន្ន សម្រាប់ពលករ។ នៅជំហ៊ាននេះ រូបថតនិងស្នាមក្រយៅដៃពលករនិងត្រូវបានរក្សាទុកក្នុងឯកសារប្រវត្តិរូបរបស់ពួកគេ ហើយពលករនឹងទទួលបានប័ណ្ណសម្គាល់ខ្លួនមិនមែនជាជនជាតិថៃ(ប័ណ្ណឆ្នូត) និងថរ ៣៨/១ ក្នុងតម្លៃ៨០បាត។ ពលករទេសន្តរប្រវេសន៍នឹងត្រូវផ្ដល់ជូនផងដែរនូវលិខិតបញ្ជាក់ ដើម្បីបញ្ជាក់ពីការអនុញ្ញាតអោយចេញចូល។ ទោះជាយ៉ាងណា ទាំងនេះសម្រាប់តែពលករណាដែលការបម្រើការងាររបស់ពួកគេត្រូវបានផ្ទៀងផ្ទាត់ ដោយឈ្មោះរបស់ពួកគាត់គឺមាននៅលើបញ្ជីឈ្មោះអ្នកបម្រើការងារដែលបានដាក់ជូនអាជ្ញាធរដោយនិយោជក ឬពលករដែលមានលក្ខណសម្បត្តិដែលស្នើដោយនិយោជក នឹងត្រូវបានអនុម័តក្នុងការវិលទៅធ្វើការនៅប្រទេសថៃ។

និយោជកថៃរបស់ពលករ ក៏មានការតម្រូវជាច្រើនដែលត្រូវបំពេញផងដែរ។ និយោជកណាដែលមិនធ្លាប់ជួលពលករកម្ពុជាដោយស្របច្បាប់ពីមុនមក ត្រូវតែដាក់ជូននូវការបែបបទស្នើសុំមួយច្បាប់ដល់ការិយាល័យការងារនៅខេត្តឬដល់បាងកក ដើម្បីទទួលបាននូវចំនួននៃការអនុញ្ញាតកន្លែងចំពោះកូតារួមនៃពលករបរទេស ក៏ដូចជាឯកសារផ្សេងៗទៀតផងដែរ។ និយោជកណាដែលបានទទួលនូវការផ្ដល់ជាចំនួនជាក់លាក់នៃការអនុញ្ញាតកន្លែងនៃកូតារួចហើយ និងធ្លាប់បានជួលពលករកម្ពុជាពីមុន ត្រូវតែដាក់ជូននូវបញ្ជីឈ្មោះរបស់ពលករ។ ទាល់តែនៅពេលដែលពលករកម្ពុជាបានទទួលនូវឯកសារដែលផ្ដល់ដោយ FCRCW ទើបនិយោជនរបស់ពួកគាត់ត្រូវបានអនុញ្ញាតអោយនាំពួកគាត់ទៅកន្លែងធ្វើការ។

ជំហ៊ានចុងក្រោយ ក្នុងដំណើរការទេសន្តរប្រវេសន៍តាម FCRCW គឺការស្នើសុំការអនុញ្ញាតការងារ។ ដើម្បីបញ្ចប់ជំហ៊ាននោះ និយោជកត្រូវតែពលករកម្ពុជារបស់ពួកគេ ដែលបានទទួលឯកសារចេញដោយ FCRCW រួចហើយទៅដាក់ពាក្យស្នើសុំការអនុញ្ញាតការងារបណ្តោះអាសន្ននៅ OSSC តាមខេត្តដែលកន្លែងការងារមានទីតាំងនៅទីនោះ។ ការអនុញ្ញាតការងារ នឹងមានសុពលភាពសម្រាប់រយៈពេលដែលនៅសល់ នៃការសុពលភាពរបស់ការអនុញ្ញាតអោយចូលមកថៃ ជាបណ្តោះអាសន្នរបស់ពួកគាត់។

### *ការិយាល័យច្រកចេញចូលតែមួយនៅកម្ពុជា*

ទិសដៅជាបឋមនៃ OSSC ក្នុងប្រទេសកម្ពុជាគឺសម្របសម្រួលដំណើរការបែបបទធ្វើលិខិតឆ្លងដែនសម្រាប់ពលករកម្ពុជាពីរប្រភេទៈ ពលករណាដែលនៅប្រទេសកម្ពុជាមានបំណងធ្វើទេសន្តរប្រវេសន៍តាមដំណើរការអនុសារណៈ និងពលករណាដែលនៅក្នុងប្រទេសថៃស្រាប់ហើយ ប៉ុន្តែមានបំណងទទួលបានឯកសារអត្តសញ្ញាណជាតិ ដើម្បីអនុញ្ញាតអោយពួកគាត់ក្លាយជាពលករមានឯកសារត្រឹមត្រូវ។ OSSC របស់កម្ពុជា ផ្តល់ដល់ជនជាតិកម្ពុជានូវការបំពេញការទាមទារ នៃដំណើរការតាមអនុសារណៈកាន់តែឆាប់រហ័ស។

សម្រាប់ពលករដែលកំពុងនៅក្នុងប្រទេសកម្ពុជា ដែលមានបំណងធ្វើទេសន្តរប្រវេសន៍ មិនតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ ពួកគាត់អាចស្នើធ្វើលិខិតឆ្លងដែនដែលបញ្ចុះតម្លៃត្រឹមតែ៤ដុល្លា តាម OSSC ដោយមានការបញ្ជាក់ថាមានការងារធ្វើពីមុននៅប្រទេសថៃ។ ផ្ទុយទៅវិញ បើមិនអាចបញ្ជាក់ថាមានការងារធ្វើពីមុននៅក្នុងប្រទេសថៃទេនោះ ពួកគាត់ត្រូវចុះកិច្ចសន្យាជាមួយទីភ្នាក់ងារជ្រើសរើសពលករអោយជួយភ្ជាប់ទំនាក់ទំនងពួកគេជាមួយនិយោជកថៃ ដែលផ្តល់ការងារដល់ពួកគាត់ធ្វើ និងឯកសារសំអាងនៃការធ្វើការងារ។

ការទទួលសេវាពីទីភ្នាក់ងារជ្រើសរើសពលករឯកជន កាន់តែក្លាយទៅការដែលលៃលកធ្វើទៅបានគិតត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ នៅពេលដែលក្រសួងការងារកម្ពុជា ធ្វើការកំណត់តម្លៃជាកញ្ចប់សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករ ចំពោះលិខិតឆ្លងដែន ការអនុញ្ញាតការងារ ទិដ្ឋាការការងារថៃ រួមនិងតម្លៃធ្វើដំណើរនិងអាហារ សរុប គឺ៤៩ដុល្លា។

ក្រុមពលករកម្ពុជាផ្សេងទៀតដែល OSSC មានបំណងចង់ជួយនោះគឺក្រុមពលករដែលកំពុងរស់នៅប្រទេសថៃដែលមានបំណងចង់បានឯកសារអត្តសញ្ញាណជាតិ។ OSSC របស់កម្ពុជាអាចផ្តល់ជូននូវប័ណ្ណពលករធ្វើការនៅបរទេស ដល់ពលករទាំងនេះ និងទទួលនូវការស្នើសុំធ្វើលិខិតឆ្លងដែន ប៉ុន្តែ

ទាល់តែពួកគាត់វិលត្រលប់ទៅកម្ពុជាវិញសិន។ នេះជាមូលហេតុដែលមជ្ឈមណ្ឌលត្រូវបានបង្កើតនៅតាមខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីសម្របសម្រួលដំណើរការកាន់តែលឿន សម្រាប់ផលប្រយោជន៍នៃពលករកម្ពុជា ធ្វើដំណើរពីប្រទេសថៃមក។

### ៤.៣. ស្ថានភាពនៃពលករវិលត្រលប់ទៅកាន់ប្រទេសថៃ

> *"ពីមុនខ្ញុំគ្មានលទ្ធភាពក្នុងការបង់ថ្លៃចុះឈ្មោះនោះទេ ប៉ុន្តែខ្ញុំគិតថាក្លាយជាពលករដែលគ្មានឯកសារ នឹងមិនប្រាកដថាប៉ះពាល់ដល់ជីវិតរបស់ខ្ញុំនៅក្នុងប្រទេសថៃនោះទេ។ ទោះជាយ៉ាងណា ខ្ញុំទើបនិងដឹងច្បាស់ថា បើខ្ញុំមិនបានចុះឈ្មោះទេនោះ ទាហ៊ាននឹងចាប់យើង"*
> *(បុរសម្នាក់ជាពលករកម្ពុជាក្នុងវ័យជាង២០ឆ្នាំ ដែលធ្លាប់បម្រើការងារសំណង់នៅខេត្តឆាក់ឈើងសៅ។ បានសម្ភាសន៍នៅខេត្តស្រះកែវ ថ្ងៃទី១៨ សីហា ២០១៤)*

នៅពេលដែលរដ្ឋាភិបាលរៀងៗខ្លួន បានរៀបចំនូវយន្តការជាច្រើនសម្រាប់ពលករក្នុងការវិលទៅថៃតាមប្រព័ន្ធផ្លូវការ និងពាក់កណ្តាលផ្លូវការ ដូចដែលបានពន្យល់ខាងលើ ពលករបានចាប់ផ្តើមវិលទៅថៃវិលយ៉ាងឆាប់រហ័ស។ ក្រុមអ្នកស្រាវជ្រាវរបស់ MMN មានអារម្មណ៍ថាជាការសំខាន់ក្នុងការរកអោយឃើញពីរបៀបដែលពួកគាត់ធ្វើទេសន្តរប្រវេសន៍ត្រលប់ទៅថៃវិញ និងទស្សនៈរបស់ពលករថាតើមូលហេតុអ្វីបានជាពួកគាត់រើសយកវិធីទេសន្តរប្រវេសន៍តាមប្រព័ន្ធហ្នឹង។ ពលករកម្ពុជាសរុប ១៣នាក់ដែលត្រូវបានសម្ភាសន៍ក្នុងទឹកដីថៃ ពួកគាត់ទាំងអស់ធ្លាប់បានរស់នៅនិងធ្វើការក្នុងទឹកដីថៃមុនពេលចេញទៅកម្ពុជាបណ្តោះអាសន្នក្នុងកំឡុងពេលលំហូរពលករថ្មីៗនេះ។ ក្នុងចំណោមអ្នកផ្តល់ព័ត៌មានមានស្រី៨នាក់និងប្រុស៥នាក់។ ៧នាក់មានអាយុចន្លោះពី១៩ទៅ៣០ឆ្នាំ ៣នាក់ចន្លោះពី៣១ទៅ៤០ឆ្នាំ និង៣នាក់ចន្លោះពី៤១ទៅ៥០ឆ្នាំ។

ក្នុងចំណោមពលករទាំងនេះដែលបានត្រលប់មកទឹកដីថៃវិញថ្មីៗ លើកលែងតែម្នាក់គត់ ក្រៅពីនោះមានកូនមួយឬច្រើននាក់។ លើសពីនេះទៅទៀត ជីវភាពរបស់គ្រួសារពួកគាត់គឺធ្វើស្រែចម្ការ លើកលែងតែពលករម្នាក់ប៉ុណ្ណោះដែលមិនមែន។ នេះគឺបានទាក់ទងទៅនិងភាគរយខ្ពស់នៃគ្រួសារអ្នកផ្តល់ព័ត៌មានដែលមានដីធ្លីនៅកម្ពុជា ដែលក្នុងនោះមានរហូតដល់១១នាក់។ ទោះជាយ៉ាងណា មានតែ៧នាក់ដែលផ្តល់ព័ត៌មានប៉ុណ្ណោះដែលមានដីធ្លីខ្លួនឯងនៅកម្ពុជា។

មុនពេលដែលអ្នកផ្តល់ព័ត៌មានចាកចេញកាលពីពេលថ្មីៗទៅកម្ពុជា ពួកគាត់បានបម្រើការងារនៅសហគ្រាសនេសាទ (អ្នកផ្តល់ព័ត៌មាន៩នាក់) ហើយសល់ពីនោះធ្វើការសំណង់។ មុនពេលចេញពី

ប្រទេសថៃផងដែរ ៧នាក់បានស្នាក់នៅក្នុងប្រទេសថៃតែ៣ទៅ៦ខែប៉ុណ្ណោះ ម្នាក់ទៀតស្នាក់នៅពី៦ខែទៅ១ឆ្នាំ ៥នាក់ទៀតស្នាក់នៅពី១ទៅ២ឆ្នាំ និងម្នាក់ទៀតពី២ទៅ៣ឆ្នាំ។



រូបថតផ្តល់ដោយ MMN

*ពលករនេសាទកំពុងហាលត្រីក្នុងខេត្តត្រាត ប្រទេសថៃ*

មូលហេតុជាចំបងបំផុតដែលអ្នកផ្តល់ព័ត៌មានជ្រើសរើសការវិលត្រលប់មកទឹកដីថៃវិញ ដោយសារតែកង្វះឱកាសការងារធ្វើនៅកម្ពុជា ដែលមាន៦នាក់ឆ្លើយដូច្នេះ។ មូលហេតុចំបងមួយវិញទៀតគឺថា និយោជករបស់ពួកគាត់នៅប្រទេសថៃ សុំអោយពួកគាត់ត្រលប់មកធ្វើការវិញ នេះបើតាមអ្នកផ្តល់ព័ត៌មាន៣នាក់។២នាក់ទៀតវិលមកថៃវិញ ដោយសារពួកគាត់បានឮថា NCPO បានបើកមជ្ឈមណ្ឌលចុះឈ្មោះពលករទេសន្តរប្រវេសន៍។

អ្នកផ្តល់ព័ត៌មានភាគច្រើន(៥នាក់) មិនបានចូលតាមដំណើរការផ្លូវការណាមួយមកប្រទេសថៃនោះទេ ពួកគាត់បានថ្លែងថាពួកគាត់ជ្រើសរើសវិធីនេះក្នុងការចូលមក ដោយសារតែពួកគាត់គ្មានឯកសារធ្វើដំណើរ ហើយការមកតាមអ្នកនាំផ្លូវគឺទាំងសុវត្ថិភាពនិងតម្លៃទាបជាងធ្វើលិខិតឆ្លងដែន។ទោះជាយ៉ាងណា ៥នាក់បានឆ្លងកាត់ព្រំដែនមកកាន់ប្រទេសថៃ និងបានទៅ FCRCW ។ មូលហេតុចំបងបំផុតដែលពួកគាត់រើសយកផ្លូវនេះ គឺដោយសារពួកគាត់ដឹងថាវាជាច្រកមួយដែលអាចអោយពួកគាត់ត្រលប់មកធ្វើការវិញបានឆាប់។ ២នាក់ទៀតបានធ្វើលិខិតឆ្លងដែន និងបានចូលមកប្រទេសថៃដោយប្រើទិដ្ឋាការទេសចរ។ ពួកគាត់រើសយកវិធីនេះដោយសារពួកគាត់មានលិខិតឆ្លងដែន និងអនុញ្ញាតអោយពួកគាត់អាចធ្វើដំណើរបានក្នុងប្រទេសថៃ។ បើទោះជាអ្នកផ្តល់ព័ត៌មានភាគច្រើនមិនបានចូលតាមប្រព័ន្ធផ្លូវការ តែ១២នាក់មានផែនការចូលរួមដំណើរការចុះឈ្មោះក្នុងពេលបច្ចុប្បន្ន។

*"ខ្ញុំគិតថាបើសិនជាពលករធ្វើឯកសារ វានឹងធ្វើអោយជីវិតយើងប្រសើរ។ យើងអាចធ្វើដំណើរទៅផ្សារនិងទៅលេងមិត្តភក្តិ" (ពលករកម្ពុជាជាស្ត្រីក្នុងវ័យ៤០ឆ្នាំប្លាយ បម្រើការងារនៅកន្លែងកែច្នៃអាហារសមុទ្រ។បានសម្ភាសន៍នៅខេត្តរ៉ាក់យ៉ងថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤)*

អ្នកផ្តល់ព័ត៌មានជាច្រើន បាននិយាយថា ដំណើរការចុះឈ្មោះថ្មីនៅក្នុងប្រទេសថៃ កាន់តែងាយស្រួលនិងមានឧបសគ្គពេលវេលាតិចតួចជាងពេលមុន។ទោះជាយ៉ាងណា ពួកគាត់ឃើញថាតម្លៃលិខិតឆ្លងដែនកម្ពុជានៅតែមានតម្លៃខ្ពស់។ លើសពីនេះទៀត ខ្លះបានកត់សម្គាល់ថាពួកគាត់នឹងមិនអាចលៃលកចំពោះតម្លៃចុះឈ្មោះបាន នៅពេលដែលត្រូវផ្តល់ដល់គ្រួសាររបស់ពួកគាត់ដែរ។ អ្នកផ្តល់ព័ត៌មានម្នាក់បានថ្លែងថាអំឡុងពេលចុះឈ្មោះគឺខ្លីណាស់ ដូច្នេះពួកគាត់មិនអាចសន្សំប្រាក់ក្នុងការបង់ថ្លៃធ្វើការចុះឈ្មោះក្នុងពេលនោះបាន។អ្នកផ្តល់ព័ត៌មានមួយចំនួនទៀត ក៏បាននិយាយដែរថា ពួកគាត់គ្មានព័ត៌មានពីដំណើរការចុះឈ្មោះនោះទេ។

អ្នកផ្តល់ព័ត៌មានត្រូវបានសាកសួរពីអនុសាសន៍របស់ពួកគាត់បើមាន សម្រាប់រដ្ឋាភិបាលថៃនិងកម្ពុជានិងសម្រាប់និយោជកថៃផងដែរ។ ពលរដែលបានសម្ភាសន៍ មានអនុសាសន៍៤ផ្នែកធំៗសម្រាប់រដ្ឋាភិបាលថៃ: អនុញ្ញាតអោយពលករបានចុះឈ្មោះទៀតទាត់(យ៉ាងតិចប្រចាំឆ្នាំ) អនុវត្តប្រាក់ឈ្នួលអប្បបរិមាគ្រប់វិស័យការងារទាំងអស់និងសម្រាប់គ្រប់ពលករទាំងអស់ បញ្ចុះតម្លៃការចុះឈ្មោះ និងផ្តល់ជូនដល់ពលករនូវការថៃរក្សាសុខភាពស្មើគ្នាទៅនិងអ្វីដែលជនជាតិថៃទទួលបាន។ សំណូមពររបស់អ្នកផ្តល់ព័ត៌មានសម្រាប់រដ្ឋាភិបាលកម្ពុជាវិញ រួមមានដូចតទៅ: បង្កើតឱកាសការងារថែមទៀតនៅកម្ពុជានិងផ្តល់ជំនួយដល់ពលករកម្ពុជានៅក្រៅប្រទេស។ ពួកគាត់មានសំណូមពរពធំៗដល់និយោជកក្នុងប្រទេសថៃ:តម្លើងប្រាក់ឈ្នួល ផ្តល់ប្រាក់ពេលសម្រាក់ព្យាបាលជម្ងឺ និងធ្វើអោយប្រសើរឡើងនូវសុវត្ថិភាពនិងសុខភាពផ្នែកការងារ។

## ៥. ការឆ្លុះបញ្ចាំង និងអនុសាសន៍ពីបណ្តាញទេសន្តរប្រវេសន៍ទន្លេមេគង្គ

ការហូរចូលភ្លាមៗនៃពលករកម្ពុជាពីប្រទេសថៃថ្មីៗក្នុងឆ្នាំនេះ គឺជាការដាស់សតិដល់មនុស្សជាច្រើនអោយមានការយកចិត្តទុកដាក់ទៅលើបញ្ហាដូចតទៅ។

ជាដំបូង វាគឺជាការរំលឹកថាសេដ្ឋកិច្ចប្រទេសថៃត្រូវការកម្លាំងពលករ។ នេះជាការពិត ដែលដឹងឮជាយូរមកហើយដោយមនុស្សជាច្រើន ប៉ុន្តែកម្រឮទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាលមុនពេលមានលំហូរពលករកម្ពុជា។ ក្នុងខែមិថុនា ការជះឥទ្ធិពលដោយសារអវត្តមាននៃពលករទាំងនេះ គឺសម្បើមណាស់ដែលសហគ្រាសថៃពឹងផ្អែកលើកម្លាំងពលករ ហើយមានមនុស្សជាច្រើនភ័យថាមិនយូរទេនឹងជះឥទ្ធិពលដល់ការខូចប្រយោជន៍សេដ្ឋកិច្ច។ ស្ថានភាពបង្ខំរដ្ឋាភិបាល ក្នុងការចេញសេចក្តីថ្លែងការណ៍សំដៅទៅ "សារៈសំខាន់នៃពលករទេសន្តរប្រវេសន៍ពីប្រទេសជិតខាង ឆ្ពោះទៅរកការជម្រុញសេដ្ឋកិច្ចថៃអោយទៅមុខ"[1x]។ ថ្វីបើមានការពឹងផ្អែកជាយូរមកហើយលើកម្លាំងពលករ ក្នុងសហគ្រាសជាច្រើននោះ គោលនយោបាយទេសន្តរប្រវេសន៍បានបរាជ័យក្នុងការផ្តល់ជូននូវការឆ្លើយតបរយៈពេលវែង និងមាននិរន្តភាព ចំពោះពលករទេសន្តរប្រវេសន៍រាប់លាននាក់កំពុងធ្វើការក្នុងប្រទេស។ ជាលទ្ធផលស្ថានភាពពលករទេសន្តរប្រវេសន៍នៅតែមិនមានភាពទៀងទាត់ និងពលករជាច្រើននាក់បានឈឺចាប់ដោយសារការប្រព្រឹត្តដ៏អាក្រក់ និងការកេងប្រវ័ញ្ច។

ទីពីរ ថ្វីបើមានការផ្តួចផ្តើមផានារបស់រដ្ឋាភិបាលកម្ពុជា ថានឹងស្វែងរកការងារសម្រាប់អ្នកដែលបានត្រលប់ទៅផ្ទះវិញនោះ ច្បាស់លាស់ណាស់ដែលប្រទេសមិនអាចផ្តល់ដល់ពលករវិលត្រលប់ទៅវិញជាច្រើននាក់ ជាមួយនិងឱកាសការងារសមរម្យនោះទេ។ ជាការពិត ដែលពលករវិលត្រលប់ជាច្រើននាក់ដែលត្រូវបានសម្ភាសន៍ក្នុងគម្រោងស្រាវជ្រាវនេះ បានផ្តល់យោបល់ថា រដ្ឋាភិបាលកម្ពុជា "បង្កើតសហគ្រាស" និង/ឬក៏"បង្កើតឱកាសការងារ" អាចចង្អុលបង្ហាញថាពលករនឹងរើសយកការរស់នៅក្នុងប្រទេសកម្ពុជា បើសិនជាពួកគាត់អាចរកការងារសមរម្យ។ ទោះជាយ៉ាងណា តថភាពគឺថាមានឱកាសជីវភាពតិចតួចណាស់ក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ហើយមនុស្សគឺគ្មានជម្រើស មានតែនាំគ្នាធ្វើទេសន្តរប្រវេសន៍ដើម្បីរកឱកាសការងារ។ អ្នកដែលអាចរកការងារធ្វើនៅតាមទីក្រុងក្នុងប្រទេសកម្ពុជានៅតែទទួលបានប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលដើម្បីរស់នៅឆ្ងាយណាស់។ ដូច្នេះ មនុស្សជាច្រើនសំលឹងមើលទេសន្តរប្រវេសន៍ទៅប្រទេសថៃ ជាវិធីតែមួយគត់ដើម្បីរស់រាន និងផ្គត់ផ្គង់ដល់គ្រួសារ។ ក្នុងការធ្វើអោយទេសន្តរប្រវេសន៍ជាជម្រើសតែមួយ ជាជាងយុទ្ធសាស្ត្ររស់រានមានជីវិតប្រាកដនិយម ប៉ុណ្ណឹងនោះ រដ្ឋាភិបាលកម្ពុជាត្រូវការពិនិត្យពិច័យអោយបានជិតដល់គំរូបច្ចុប្បន្ននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស និងធ្វើការឆ្ពោះទៅសម្រេចបាននូវប្រាក់ឈ្នួលចិញ្ចឹមជីវិតសម្រាប់ពលករទាំងអស់ក្នុងប្រទេសកម្ពុជា។

ទីបីរ ផ្អែកទៅលើការសម្ភាសន៍ ច្បាស់លាស់ណាស់ដែលថាពលករភាគច្រើនដែលមានបំណងធ្វើតាមច្បាប់ទម្លាប់ និងចង់បានស្ថានភាពស្របច្បាប់នៅក្នុងទឹកដីថៃ។ ទោះជាយ៉ាងណា បច្ចុប្បន្នពលករជាច្រើននៅតែឃើញថាប្រព័ន្ធទេសន្តរប្រវេសន៍ផ្លូវការនៅតែមានតម្លៃខ្ពស់និងមិនទទួលបាន។ភាពមិនទទួលបាននេះ តែងតែរើខ្លាំងឡើង ដែលជាការពិតពលករមិនបានទទួលប្រាក់ឈ្នួលអប្បបរិមាននៅក្នុងប្រទេសថៃ ហើយពួកគាត់មិនបានទទួលប្រាក់ឈ្នួលពេលដែលសុំឈប់សម្រាក ដែលពួកគាត់គួរតែទទួលបានតាមច្បាប់ការងារជាតិ ដូចជានៅពេលសម្រាកព្យាបាលជម្ងឺជាដើម។ ដូច្នេះ សមត្ថភាពរបស់ពលករក្នុងការលៃលកចំណាយលើថ្លៃចាំបាច់ ក្នុងការធ្វើឯកសារស្របច្បាប់នោះគឺទុកមួយឡែកសិន។ នេះជាពេលមួយ ដែលរដ្ឋាភិបាលត្រូវធានាថាពលករទាំងអស់ទទួលបាននូវប្រាក់ឈ្នួលអប្បបរិមានិងទទួលប្រាក់ឈ្នួលពេលសម្រាកព្យាបាលជម្ងឺដែលជាចំនុចមួយនៃសិទ្ធិ។ អនុវត្តច្បាប់ទាំងនេះគឺប្រហែលជាអាចជម្រុញពលករបន្ថែមទៀត ក្នុងការចំណាយពេលវេលារបស់ពួកគេ ដើម្បីបន្តទៅរកប្រព័ន្ធទេសន្តរប្រវេសន៍ស្របច្បាប់ និង/ឬដំណើរការចុះឈ្មោះ។

ជាចុងក្រោយ លំហូរនៃពលករកម្ពុជា បានគូសបញ្ជាក់ពីការខ្វះជំនឿចិត្តក្នុងចំណោមពលករចំពោះអង្គភាពអនុវត្តច្បាប់ និងការជះឥទ្ធិពលដែលអាចកើតមាននៃវោហារតឹងរ៉ឹងខ្លាំងរបស់អាជ្ញាធរ ចំពោះពលករ។ ច្រើនឆ្នាំមកហើយ ពលករក្នុងប្រទេសថៃបានឃើញថាការអនុវត្តច្បាប់ព្យាយាម ដើម្បីគ្រប់គ្រងពលករ ក្នុងពេលដែលបានធ្វើកិច្ចការតិចតួចដើម្បីការពារពួកគាត់ ហើយកម្រនាំយកនិយោជកមករកយុត្តិធមិ ចំពោះទង្វើផ្តល់ប្រាក់ឈ្នួលក្រោមស្តង់ការ ប្រព្រឹត្តផ្តាំឆ្គងលើពលករ និងកេងប្រវ័ញ្ចលើពលកររបស់ខ្លួន។ទាំងនេះបានរើខ្លាំងដោយវោហារសាស្រ្តដដែលៗរបស់ NCPO សំដៅទៅដល់ "បញ្ហាពលករទេសន្តរប្រវេសន៍" ដែលធ្វើអោយបង្កការភិតភ័យក្នុងការបង្ក្រាបដោយប្រើហិង្សាទៅលើពលករ បើសិនជាប្រព័ន្ធទេសន្តរប្រវេសន៍ស្របច្បាប់ គឺត្រូវជម្រុញតទៅមុខទៀត ជាការសំខាន់ណាស់ដែលអ្នកពាក់ព័ន្ធទាំងអស់ធ្វើការឆ្ពោះទៅកសាងឡើងវិញនូវជំនឿចិត្តរបស់ពលករ ចំពោះស្ថាប័ណអនុវត្តច្បាប់។ ពួកគាត់ត្រូវការជំនឿចិត្តដែលថា អង្គភាពរដ្ឋាភិបាលនឹងធានាដល់ពលករទេសន្តរប្រវេសន៍ថានឹងទទួលបានប្រាក់ឈ្នួលអប្បបរិមា ហើយកន្លែងការងារត្រូវបានធ្វើអធិការកិច្ចដើម្បីធានាថា មានលក្ខខណ្ឌការងារសុវត្ថិភាព ដែលនិយោជកទាំងអស់នឹងធ្វើអោយមានសុវត្ថិភាពសង្គម សម្រាប់និយោជិតរបស់ខ្លួន ហើយដែលនិយោជកនឹងមិនជំរិតយកឯកសាររបស់ពលករ ហើយដែលការរំលោភទៅលើសិទ្ធិណាមួយរបស់ពលករត្រូវតែដាក់ទោស។ ប្រសិនបើជំនឿចិត្តដូច្នោះត្រូវបានស្តារឡើងវិញមែននោះ ការប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធ្វើអោយស្របច្បាប់នូវស្ថានភាពរបស់ពលករនឹងមានប្រសិទ្ធិភាព ហើយរដ្ឋាភិបាលនឹងទទួលបាននូវការគាំទ្រពីពលករទេសន្តរប្រវេសន៍ដោយពួកគាត់ផ្ទាល់។

ជាមួយនិងការរកឃើញទាំងនេះក្នុងចិត្ត យើងខ្ញុំសូមជម្រុញអោយអ្នកពាក់ព័ន្ធទាំងអស់ពិចារណានូវអនុសាសន៍ដូចតទៅ។

**សម្រាប់រដ្ឋាភិបាលកម្ពុជា ដើម្បី៖**

- ពិនិត្យឡើងវិញនូវគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីបង្កើតការងារសមរម្យជាមួយប្រាក់ឈ្នួលរស់នៅសមរម្យ និងធ្វើអោយប្រសើរឡើងនូវស្តង់ដារនៃការរស់នៅសម្រាប់ប្រជាជនរបស់ខ្លួន។
- ពង្រឹងអំណាចនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីការពារសិទ្ធិជនជាតិរបស់ខ្លួនដែលកំពុងធ្វើការទាំងនៅក្នុងប្រទេស និងនៅលើទឹកដីបរទេស។
- បង្កើតគោលនយោបាយទាក់ទងនិងការងារនិងទេសន្តរប្រវេសន៍ ដោយមានការពិគ្រោះយោបល់ជាមួយពលករ ដែលត្រូវរងផលប៉ះពាល់ពីគោលនយោបាយទាំងនោះ។
- រៀបចំផែនការនិងអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍ជាតិ ដែលត្រូវបានរៀបចំសម្រាប់ការវិលត្រលប់ជាយថាហេតុនៃពលករទេសន្តរប្រវេសន៍កម្ពុជា។ និង
- ផ្តល់ជូនដល់ពលករនូវកម្ចីការប្រាក់ទាប ក្នុងគោលបំណងបញ្ចៀសភាពជាប់បំណុល ដោយសារតែកម្ចីអត្រាការប្រាក់ខ្ពស់ ដែលជារឿយៗគឺសម្រាប់សម្របសម្រួលដល់ការធ្វើទេសន្តរប្រវេសន៍។

**សម្រាប់រដ្ឋាភិបាលថៃ ដើម្បី៖**

- រៀបចំធ្វើការវាយតម្លៃអោយបានជិតដល់មួយ នៃផលប៉ះពាល់ពីគោលនយោបាយ ទេសន្តរប្រវេសន៍របស់ខ្លួន។
- ធានាថាពលករទាំងអស់ទទួលបាននូវប្រាក់ឈ្នួលអប្បបរិមាដែលពួកគេត្រូវទទួលបាន និងធ្វើការឆ្ពោះទៅរកការផ្តល់ប្រាក់ឈ្នួលរស់នៅសមរម្យសម្រាប់ទាំងអស់គ្នា។
- ពិនិត្យមើលឡើងវិញនូវគោលនយោបាយណាដែលបង្កើនហានីភ័យដល់ពលករ ដែលនឹងអាចក្លាយទៅជាគ្មានឯកសារ នាំអោយពួកគាត់ប្រឈមមុខទៅនិងការចាប់ខ្លួន និងការបញ្ជូនត្រលប់។
- ធានាថាការបញ្ជូនត្រូវបានអនុវត្តតែក្នុងជម្រើសចុងក្រោយបំផុត ក្នុងការចាត់ចែងចំពោះប្រជាជនជាពលករគ្មានឯកសារ។ និង
- បង្កើតគោលនយោបាយពាក់ព័ន្ធនិងពលករការងារ អោយមានមូលដ្ឋានយូរអង្វែង។

**សម្រាប់រដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជាដើម្បីៈ**

- ពិនិត្យមើលឡើងវិញនូវយន្តការទេសន្តរប្រវេសន៍បច្ចុប្បន្ន ក្នុងគោលបំណងធ្វើអោយវាកាន់តែងាយស្រួល កាន់តែលឿន កាន់តែតម្លៃទាប និងកាន់តែអាចទទួលបានសម្រាប់ពលករធម្មតា
- សហការប្រតិបត្តិការក្នុងការធានាថា ការបញ្ជូនត្រលប់ពលករត្រូវបានអនុវត្តក្នុងសភាពដែលមានសុវត្ថិភាពនិងភាពថ្លៃថ្នូរ និងក្នុងទិដ្ឋភាពច្បាប់ ក្នុងករណីដែលការអនុវត្តច្បាប់ដូចនោះមិនអាចជៀសវាងបាន។

**សម្រាប់អាស៊ានដើម្បីៈ**

- បញ្ជាក់អោយច្បាស់ពីទំហំនៃសេចក្តីប្រកាសអាស៊ាន ស្តីពីការការពារនិងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ព្រមទាំងជម្រុញអោយរដ្ឋសមាជិកធ្វើការពិនិត្យមើលឡើងវិញពីគោលនយោបាយទេសន្តរប្រវេសន៍រៀងៗខ្លួន ក្នុងការធ្វើអោយប្រសើរឡើងនូវជីវិតរបស់ពលករនៅតាមសហគ្រាស។ និង
- ជម្រុញការវិនិយោគនៅក្នុងប្រទេសកំណើតរបស់ពលករ ដែលមានក្រមសីលធម៌ជំនួញល្អ និងរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅទីនោះ។